ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# គោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល ២០២០-២០២៤

រៀបចំដោយក្រុមការងារបញ្ជ្រាបយេនឌ័រ (GMAG)នៃក្រសួងសុខាភិបាល
និងគាំទ្រដោយ ADB-GMS-HSP

ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤
គ.ស. ២០២០

# មាតិកា


មាតិកា.....i
អារម្ភកថា.....iii
សេចក្ដីថ្លែងអំណរគុណ.....v
ក្រុមការងាររៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្របញ្ច្រាបយេនឌ័រ.....vii
ពាក្យបំព្រួញ និងអក្សរកាត់.....xii
១. សាវតា.....១
២. ស្ថានភាពយេនឌ័រនៅព្រះរាជាណាចក្រកម្ពុជា.....១
២.១-សេចក្តីផ្តើម.....១
២.២-សមិទ្ធិផលនៃការបញ្ជ្រាបយេនឌ័រតាមវិស័យនានា.....៣
៣. យេនឌ័រ និងសុខភាពនៅព្រះរាជាណាចក្រកម្ពុជា.....៥
៣.១-សមិទ្ធផលសម្រេចបាន.....៥
៣.២-បញ្ហាប្រឈម.....៧
៤. គោលនយោបាយ.....៨
៤.១-ទស្សនៈវិស័យ.....៨
៤.២-បេសកកម្ម.....៨
៤.៣ -គោលបំណង.....៩
៤.៤-វិសាលភាព.....៩
៤.៥-គោលដៅនៃគោលនយោបាយ.....៩
៤. ៦-យុទ្ធសាស្ត្ររបស់គោលនយោបាយ ( Guiding Principle ).....៩
៤.៧-យុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបយេនឌ័រ.....៩
៥. ផែនការសកម្មភាព.....១៥
៦. ការលើកកម្ពស់អភិបាលកិច្ចនៅទូទាំងប្រព័ន្ធសុខាភិបាលសម្រាប់ការងារបញ្ជ្រាបយេនឌ័.....១៨
៧. កញ្ចប់ថវិកាសម្រាប់ការងារបញ្ជ្រាបយេនឌ័រ.....១៩
៨. ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ.....១៩
៩. សេចក្តីសន្និដ្ឋាន.....២១
១០. ឯកសារយោង.....២២
១១. ឧបសម្ព័ន្ធ.....២៣
១១.១-បញ្ជីវាក្យស័ព្ទបច្ចេកទេសយេនឌ័រ.....២៣

# អារម្ភកថា

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានសន្តិភាពពេញលេញ និងមានការអភិវឌ្ឍរីកចម្រើនទាំងលើវិស័យហេដ្ឋារចនាសម្ព័ន្ធនិងសេដ្ឋកិច្ច-សង្គម ជាពិសេសការយកចិត្តទុកដាក់ឱ្យមានសមភាពយេនឌ័រលើគ្រប់វិស័យតាមរយៈការដាក់ចេញនូវគោលនយោបាយកំណែទម្រង់នានាក្នុងអាណត្តិទី៦របស់រាជរដ្ឋាភិបាលកម្ពុជា។កម្មវិធីគោលនយោបាយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ បានកំណត់យ៉ាងច្បាស់អំពីកាតព្វកិច្ចបន្តបេសកកម្មដ៏ឧត្តុងឧត្តមដើម្បីពន្លឿនកិច្ចអភិវឌ្ឍន៍ និងជំរុញកំណែទម្រង់ស៊ីជម្រៅដោយប្រកាន់ខ្ជាប់នូវចក្ខុវិស័យយូរអង្វែង សំដៅលើកកម្ពស់សមត្ថភាពដឹកនាំតាមស្ថាប័នពង្រីកមូលដ្ឋានសេដ្ឋកិច្ច និងបង្កើនសុខុមាលភាពប្រជាពលរដ្ឋ។រាជរដ្ឋាភិបាលបាននិងកំពុងខិតខំលើកកម្ពស់សមភាព និងសមធម៌យេនឌ័រតាមរយៈការបញ្ជ្រាបយេនឌ័រទៅតាមវិស័យស្របតាមអភិក្រម **"ស្ត្រីជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិ"** ក្នុងនោះក្រសួងសុខាភិបាលបានយកចិត្តទុកដាក់ខ្ពស់ក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីសុខភាព និងសកម្មភាពនានា ដោយផ្តោតការយកចិត្តទុកដាក់លើស្ត្រីតាមរយៈការលើកកម្ពស់សមត្ថភាព ការបង្កើនចំនួនស្ត្រីជាមន្ត្រីរាជការនិងប្រជាជនដែលត្រូវការសេវាសុខាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រសួងសុខាភិបាលសូមប្រកាសដាក់ឱ្យប្រើប្រាស់គោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល២០២០-២០២៤ដែលមានយុទ្ធសាស្ត្រកែលម្អផែនការថវិការបស់ក្រសួងសុខាភិបាលដើម្បីឆ្លើយតបទៅនឹងការងារយេនឌ័រ ពង្រឹងសមត្ថភាពនៃឱកាសនៅក្នុងការជ្រើសរើស បណ្តុះបណ្តាល និងដំឡើងមុខតំណែងរបស់មន្ត្រីរាជការក្រសួងសុខាភិបាល បង្កើនការឆ្លើយតបរបស់កម្មវិធី និងផ្តល់សេវាសុខាភិបាលឆ្លើយតបទៅនឹងការងារយេនឌ័រ បង្កើនការការពារជាប្រព័ន្ធលើអំពើហិង្សាលើស្ត្រីនិងកុមារពង្រឹងការទប់ស្កាត់និងផលប៉ះពាល់លើផ្នែកសុខភាពចិត្ត-សង្គមដោយអំពើជួញដូរមនុស្សព្រមទាំងពង្រឹងសមត្ថភាពរបស់មន្ត្រីសុខាភិបាលដើម្បីដោះស្រាយបញ្ហាប្រឈមនានាឆ្លើយតបនឹងយេនឌ័រក្នុងវិស័យសុខាភិបាល។

ក្រសួងសុខាភិបាលសូមណែនាំថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍទាំងអស់របស់ក្រសួងសុខាភិបាលផ្តល់ការគាំទ្រ និងអនុវត្តគោលនយោបាយនិងផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបយេនឌ័រ ២០២០-២០២៤ នេះឱ្យសម្រេចបានជោគជ័យនិងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ចន្ទ ៦ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២០

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

# សេចក្តីថ្លែងអំណរគុណ

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក-លោកស្រីសាស្ត្រាចារ្យ វេជ្ជបណ្ឌិត មន្ត្រីក្រសួងសុខាភិបាល និងអង្គការដៃគូរួមមាន មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន(UNFPA) ធនាគារពិភពលោក(World Bank) ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ(USAID) អង្គការសុខភាពពិភពលោក(WHO) ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ(AusAID) អង្គការសុខភាពគ្រួសារអន្តរជាតិ-៣៦០(FHI-360) អង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM) ដែលបានចែករំលែកបទពិសោធន៍ និងផ្តល់ធាតុចូល ព្រមទាំងទិន្នន័យសំខាន់ៗក្នុងនោះ គម្រោងបង្ការនិងទប់ស្កាត់ជំងឺឆ្លងក្នុងមហាអនុតំបន់មេគង្គរបស់ធនាគារអភិវឌ្ឍអាស៊ី( ADB-GMS-HSP)នៃនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងរបស់ក្រសួងសុខាភិបាលចំពោះកិច្ចសហការនិងការផ្តល់ជំនួយបច្ចេកទេស ជាពិសេសដោយមានការសម្របសម្រួលពីក្រុមលេខាធិការដ្ឋាននៃក្រុមការងារបញ្ច្រាបយេនឌ័រក្រសួងសុខាភិបាលជាមួយដៃគូអភិវឌ្ឍពាក់ព័ន្ធបានពិនិត្យពិភាក្សា និងកែសម្រួលផែនការយុទ្ធសាស្ត្រ និង ផែនការ សកម្មភាពបញ្ច្រាបយេនឌ័រក្នុងវិស័យសុខាភិបាល ២០១៤-២០១៨ ទៅជា **គោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពី ការបញ្ច្រាបយេនឌ័រក្នុងវិស័យសុខាភិបាល ២០២០-២០២៤** ដ៏មានសារៈសំខាន់នេះ។

ថ្ងៃ សុក្រ ៣ កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញថ្ងៃទី២៤ ខែ មេសា ឆ្នាំ២០២០

**រដ្ឋលេខាធិការ និងជា**
**ប្រធានក្រុមការងារបញ្ច្រាបយេនឌ័រក្រសួងសុខាភិបាល**

សាស្ត្រាចារ្យ **តាន់ ឡូចនេង**

# ក្រុមការងាររៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្របញ្ច្រាបយេនឌ័រ

## I. ក្រសួងសុខាភិបាល

| | | |
|---|---|---|
| ១ | លោកជំទាវ **តាន់ ខួចឆេង** | រដ្ឋលេខាធិការ |
| ២ | លោកជំទាវ **ឱ វណ្ណឌីន** | រដ្ឋលេខាធិការ |
| ៣ | លោកជំទាវ **ប៉ែន រិកស៊ី** | អនុរដ្ឋលេខាធិការ |
| ៤ | លោកជំទាវ **ប្រាក់ សោភ័ណនារី** | អនុរដ្ឋលេខាធិការ |
| ៥ | ឯកឧត្តមវេជ្ជ. **ហុក គឹមចេង** | អគ្គនាយកបច្ចេកទេសសុខាភិបាល |
| ៦ | ឯកឧត្តម **អ៊ូ ចិតព** | អគ្គាធិការ |
| ៧ | ឯកឧត្តម **សុខ សំអាង** | អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ |
| ៨ | ឯកឧត្តមសាស្ត្រ. **សាផុន វឌ្ឍន:** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ៩ | ឯកឧត្តមសាស្ត្រ. **ឈាង រ៉ា** | អគ្គនាយកមន្ទីរពេទ្យកាល់ម៉ែត |
| ១០ | ឯកឧត្តមវេជ្ជ. **ឡូ វាសនាគិរី** | ទីប្រឹក្សាក្រសួងសុខាភិបាលនិងជាប្រធាននាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល |
| ១១ | ឯកឧត្តមវេជ្ជ. **ម៉ី សំបូរ** | ទីប្រឹក្សាក្រសួងសុខាភិបាលនិងជាប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក |
| ១២ | លោកវេជ្ជ. **សុខ ស្រ៊ុន** | ប្រធាននាយកដ្ឋានមន្ទីរពេទ្យ |
| ១៣ | ឯកឧត្តមវេជ្ជ. **ម៉ៅ តាន់អ៊ាង** | ទីប្រឹក្សាក្រសួងសុខាភិបាលនិងជាប្រធានមជ្ឈ.ជាតិកំចាត់រោគរបេង និងហង់សិន |
| ១៤ | លោក **ហុក ខៀវ** | ប្រធាននាយកដ្ឋាននីតិកម្ម |
| ១៥ | លោកវេជ្ជ. **លី សូវ៉ាន់** | ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| ១៦ | លោកវេជ្ជ. **ស៊ុង វិនត:** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ១៧ | លោកវេជ្ជ. **ភុល ហៅរ៉ូ** | ប្រធាននាយកដ្ឋានការពារសុខភាព |
| ១៨ | លោកវេជ្ជ. **ស៊ុំ សារិទ្ធ** | ប្រធាននាយកដ្ឋានរដ្ឋបាល |
| ១៩ | កញ្ញាវេជ្ជ. **ទូច សុខនាង** | ប្រធាននាយកដ្ឋានអភិវឌ្ឍធនធានមនុស្ស |
| ២០ | លោកឱសថបណ្ឌិត **ហេង ប៊ុនគៀត** | ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យ និងគ្រឿងសំអាង |
| ២១ | លោក **ប៊ុន រិ** | ប្រធាននាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ |
| ២២ | លោកវេជ្ជ. **ឈិត សុផល** | ប្រធាននាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន |
| ២៣ | លោកវេជ្ជ. **អ៊ីវ សុបុណ្ណ** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ២៤ | លោកស្រីសាស្ត្រាចារ្យ **ទុង រដ្ឋាវី** | ប្រធានមជ្ឈ.ជាតិគាំពារមាតា និងទារក |
| ២៥ | លោកស្រីវេជ្ជ. **ឈា ឆដាភា** | ប្រធានមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព |
| ២៦ | លោកវេជ្ជ. **សុខ ប៉ូ** | ប្រធានមជ្ឈមណ្ឌលជាតិផ្តល់ឈាម |
| ២៧ | លោកវេជ្ជ. **លី ពេញស៊ុន** | ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| ២៨ | លោកវេជ្ជ. **ហ៊ុយ រ៉េភុល** | ប្រធានមជ្ឈ.ជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និង បាណកសាស្ត្រ |
| ២៩ | លោកវេជ្ជ. **ម៉ឹង វណ្ណារុំ** | ប្រធានមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ |
| ៣០ | លោកសាស្ត្រាចារ្យ **ឌី ម៉េង** | នាយកមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត |
| ៣១ | លោកសាស្ត្រាចារ្យ **លូ លីឃាង** | នាយកមន្ទីរពេទ្យព្រះអង្គឌួង |
| ៣២ | លោកសាស្ត្រាចារ្យ **តាន់ សុគុន** | នាយកមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុម: |
| ៣៣ | លោកស្រីវេជ្ជ. **កើត ពេជ្រចិន្តា** | នាយកទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល |

| | | |
|---|---|---|
| ៣៤ | លោកសាស្ត្រាចារ្យ **គីម សាខួន** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ |
| ៣៥ | លោក **នុន សុខឡូនា** | អនុប្រធាននាយកដ្ឋានរដ្ឋបាល |
| ៣៦ | លោកស្រីវេជ្ជ. **ជន ស៊ីនួន** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ |
| ៣៧ | លោកស្រីវេជ្ជ. **ថែម ទិរាវណ្ណា** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ៣៨ | លោកស្រីវេជ្ជ. **តេខ ស្រី** | អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| ៣៩ | លោកស្រីឱសថការី. **ឈឹម ម៉ាលី** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក |
| ៤០ | លោកទន្តបណ្ឌិត **គាំ ស៊ីនួន** | អនុប្រធាននាយកដ្ឋាននីតិកម្ម |
| ៤១ | លោកស្រីវេជ្ជ. **ឡាក់ មួយស៊ាង** | អនុប្រធាននាយកដ្ឋានការពារសុខភាព |
| ៤២ | លោកស្រី **ម៉ម សុថាវី** | អនុប្រធាននាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ |
| ៤៣ | លោកវេជ្ជ. **ចេង មុនី** | អនុប្រធាននាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល |
| ៤៤ | លោកស្រីវេជ្ជ. **ហាង រ័ត្នៃនារី** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវេជ្ជសាស្ត្រ |
| ៤៥ | លោកស្រីវេជ្ជ. **គីម រតនា** | អនុប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក |
| ៤៦ | លោកវេជ្ជ. **ឡាន វណ្ណាសេង** | អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| ៤៧ | លោកស្រីវេជ្ជ. **ហួត ចាន់ធានី** | នាយករងប្រធានមន្ទីរពេទ្យកុមារជាតិ |
| ៤៨ | លោកស្រីវេជ្ជ. **ម៉ូខេង ថាវរីន** | អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីសាស្ត្រ និងបាណកសាស្ត្រ |
| ៤៩ | លោកស្រីវេជ្ជ. **សុខ សូរតនា** | អនុប្រធានមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ |
| ៥០ | លោកស្រីសាស្ត្រវេជ្ជ. **ចក ធីតា** | នាយករងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត |
| ៥១ | លោកស្រីវេជ្ជ. **ម៉ែន នារីសុជាតិ** | នាយករងមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ |
| ៥២ | លោកស្រីឱសថការី **ឆាយ រដ្ឋធានី** | អនុប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យ និងគ្រឿងសំអាង |
| ៥៣ | លោកវេជ្ជ. **ខ៉ែត សុវណ្ណា** | នាយកដ្ឋានការពារសុខភាព |
| ៥៤ | លោកស្រី **ហែម ណាវី** | ប្រធានការិយាល័យគិលានុដ្ឋាកនិងឆ្មប នាយកដ្ឋានមន្ទីរពេទ្យ |
| ៥៥ | លោកវេជ្ជ **អៀន សុខគី** | ប្រធានការិ. គ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន នា.ការពារសុខភាព |
| ៥៦ | លោក **គង់ ស្រួន** | ប្រធានការិ.ត្រួតនិនិត្យនៃអគ្គាធិការដ្ឋាន |
| ៥៧ | លោកវេជ្ជ. **នុត មុនី** | ប្រធានលេខាធិការដ្ឋានអគ្គនាយកបបច្ចេកទេសុខាភិបាល |
| ៥៨ | លោកវេជ្ជ. **សោម សីហារ័ត្ន** | អនុការិ. និយ័តកម្ម និងក្រមសីលធម៌ នាយកដ្ឋានមន្ទីរពេទ្យ |
| ៥៩ | លោកស្រី **ហួត មាលតី** | នាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន |
| ៦០ | លោក **អ៊ុក សុផល** | មន្ត្រីនាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន |
| ៦១ | លោកស្រីវេជ្ជ. **អៀ ដារ៉ាវី** | មន្ត្រីនាយកដ្ឋានមន្ទីរពេទ្យ |
| ៦២ | កញ្ញា **ឆាយ តារាម្យ** | មន្ត្រីនាយកដ្ឋានរដ្ឋបាល |
| ៦៣ | លោកស្រីវេជ្ជ. **ឡាំ គីរុណា** | មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក |
| ៦៤ | លោកស្រីវេជ្ជ. **ណុប សុធារតនៈ** | មជ្ឈមណ្ឌលជាតិកំចាត់រោគរបេងនិងហង់សិន |
| ៦៥ | លោកស្រីឱសថ. **យស់ សុល្លនា** | មន្ទីរពេទ្យព្រះអង្គឌួង |
| ៦៦ | លោកស្រី **ជាម ស៊ីនិត** | មជ្ឈមណ្ឌលជាតិផ្តល់ឈាម |
| ៦៧ | លោក. **អ៊ូច រតនា** | មន្ត្រីនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| ៦៨ | លោកស្រីសាស្ត្រ. **អ៊ឹម សិទ្ធិភារ្យ** | មន្ទីរពេទ្យកាល់ម៉ែត |

## II. អង្គការដៃគូអភិវឌ្ឍ

| | | |
|---|---|---|
| ៦៩ | លោកវេជ្ជ. **ស្មួស ប្រិមប្រិយ** | Deputy Chief of Party, USAID-EQHA, FHI360 |
| ៧០ | លោក **លុយ តិចឆេង** | Gender Specialist, ADB-GMS-HSP |
| ៧១ | លោកស្រី **ឈាង កន្និដ្ឋា** | Technical Officer, WHO |
| ៧២ | លោក **ម៉ូ ម៉ែ** | Technical Officer, WHO |
| ៧៣ | លោកស្រីវេជ្ជ. **សំ សុជា** | Reproductive Health Specialist |
| ៧៤ | លោកស្រី **ស៊ឹម ចិន្តា** | Gender Specialist, World Bank |
| ៧៥ | លោកស្រី **ហោ សតា** | Gender Specialist, USAID-EQHA, FHI360 |
| ៧៦ | លោកស្រី **អាំង សុខរើន** | Gender Analyst, UNFPA |
| ៧៧ | លោកស្រី Kristine Parco | Chief of Mission, IOM to Cambodia |
| ៧៨ | លោកស្រី **ឌំ ចន្ទធីតា** | មន្ត្រីអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) |
| ៧៩ | លោកវេជ្ជ. **សោមជុំ ដាការ** | Community Health Specialist, ADB-GMS-HSP |

# ពាក្យបំព្រួញ និងអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AusAID | ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| CCWC | គណៈកម្មាធិការឃុំទទួលបន្ទុកនារី និងកុមារ |
| CDC | ការត្រួតពិនិត្យជំងឺឆ្លង |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងគ្រប់ប្រភេទប្រឆាំងស្ត្រី |
| CNCW | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| CDCD | នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| CDHS | ការអង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា |
| DMHSA | នាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន |
| CENAT | មជ្ឈមណ្ឌលជាតិកំចាត់រោគរបេងនិងហង់សិន |
| CNM | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ |
| DP | នាយកដ្ឋានគ្រប់គ្រងបុគ្គលិក |
| DPHI | នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល |
| FHI 360 | អង្គការសុខភាពគ្រួសារអន្តរជាតិ ៣៦០ |
| GBV | អំពើហឹង្សាលើយេនឌ័រ |
| GM | ការបញ្ជ្រាបយេនឌ័រ |
| GMS-HSP | គម្រោងបង្ការ និងទប់ស្កាត់ជំងឺឆ្លងក្នុងមហាអនុតំបន់មេគង្គ |
| GMAG | ក្រុមសកម្មភាពបញ្ជ្រាបយេនឌ័រ |
| GMAP | ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ |
| DHS | នាយកដ្ឋានមន្ទីរពេទ្យ |
| DIC | នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| HIV/AIDS | មេរោគអេដស៍/ជំងឺអេដស៍ |
| HRD | នាយកដ្ឋានអភិវឌ្ឍធនធានមនុស្ស |
| IOM | អង្គការអន្តរជាតិទេសន្តរប្រវេសន៍ |
| MCH | មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| M&E | ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | ក្រសួងសុខាភិបាល |
| MOWA | ក្រសួងកិច្ចការនារី |
| NCHADS | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| NCHP | មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព |
| NSSF | បេឡាជាតិរបបសន្តិសុខសង្គម |
| NRHP | |
| PCA | ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល |

| | |
|---|---|
| PMD | នាយកដ្ឋានការពារសុខភាព |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RS | យុទ្ធសាស្រ្តចតុកោណ |
| SDG | ផែនការអភិវឌ្ឍន៍ដោយចេរភាព |
| WB | ធនាគារពិភពលោក |
| WHO | អង្គការសុខភាពពិភពលោក |
| UHS | សាកលវិទ្យាល័យវិទ្យាសាស្រ្តសុខាភិបាល |
| UNFPA | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍអន្តរជាតិ |

# ១. សាវតា

ក្រសួងសុខាភិបាល បានបង្កើតផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាលចំនួនពីរដំណាក់កាលមកហើយ ដោយមានការសហការជាមួយក្រសួងកិច្ចការនារី និងអង្គការដៃគូ ដូចជា UNFPA, AusAID, USAIDតំណាក់កាលនីមួយៗមានដូចខាងក្រោម៖

១- ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាលឆ្នាំ២០០៦-២០១០ជាដំណាក់កាលទី១

២-យុទ្ធសាស្ត្រនិងផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាលកម្ពុជា ឆ្នាំ២០១៤-២០១៨ ជាដំណាក់កាលទី២

នៅដំណាក់កាលទី៣ដើម្បីធ្វើឱ្យប្រសើរឆ្លើយតបនឹងការរីកចម្រើននៃស្ថានភាពយេនឌ័រពាក់ព័ន្ធនឹងសុខភាពរបស់ស្ត្រីក្នុងការពង្រីកសេវាព្យាបាលថែទាំសុខភាពជាពិសេសដល់ប្រជាជនក្រីក្រ ក្រសួងសុខាភិបាលបានរៀបចំកែសម្រួលយុទ្ធសាស្ត្រ និងផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាលឆ្នាំ២០១៤-២០១៨ ទៅជាគោលនយោបាយនិងផែនការយុទ្ធសាស្ត្រស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាលឆ្នាំ២០២០-២០២៤។

# ២. ស្ថានភាពយេនឌ័រនៅព្រះរាជាណាចក្រកម្ពុជា

## ២.១-សេចក្តីផ្តើម

**សន្តិភាព** គឺជាមូលដ្ឋានគ្រឹះដើម្បីធានាដល់ការរីកចម្រើននៃលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស ការអភិវឌ្ឍដោយចីរភាព សមធម៌ និងធានាជីវភាពរស់នៅដោយសុខសាន្ត ប្រកបដោយកិត្តិយសរបស់ប្រជាជនកម្ពុជា។ការបាត់បង់សន្តិភាព ស្មើនឹងបាត់បង់អ្វីៗទាំងអស់។ ដូចនេះ យើងត្រូវរួមគ្នាការពារសុខសន្តិភាពជាតិក្រោមម្លប់សន្តិភាព។ ព្រះរាជាណាចក្រកម្ពុជាបានចាកចេញពីប្រទេសក្រីក្របំផុត ក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ក្នុងឆ្នាំ២០១៥ ហើយកំពុងឆ្ពោះទៅប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងត្រៀមខ្លួនឈានទៅជាប្រទេសដែលមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០តាមយរយៈការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ "**ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព**" បាននឹងកំពុង **កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០** ។

ឆ្លើយតបទៅនឹង**គោលដៅអភិវឌ្ឍដោយចីរភាព** (SDG) ក្នុងគោលដៅទី១៖ កាត់បន្ថយភាពក្រីក្រគោលដៅទី៥៖ កាត់បន្ថយវិសមភាពយេនឌ័រ និងគោលដៅទី១០៖ កាត់បន្ថយគម្លាតសង្គម ព្រមទាំងការប្តេជ្ញាចិត្តរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងកិច្ចប្រជុំអ្នកដឹកនាំពិភពលោកស្តីពី សមភាពយេនឌ័រនិងការលើកកម្ពស់ស្ត្រីនៅទីក្រុងញូយ៉ក(New York) ក្នុងឆ្នាំ២០១៥ ដែលបានផ្តល់អាទិភាពទៅលើការងារមួយចំនួនដូចជា (១) ការបង្កើនការវិនិយោគទៅលើ

សមភាពយេនឌ័រ (២) ការការពារសិទ្ធិរបស់ស្ត្រីពេញលេញ និងស្មើភាពនៅក្នុងការសម្រេចចិត្តនៅគ្រប់កម្រិត (៣) ការពង្រឹង យន្តការគណនេយ្យភាពសំរាប់សមភាពយេនឌ័រ និង(៤) ការបន្តលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច និងបរិយាប័ន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី។ជាមួយគ្នានេះ **សន្និបាតគណៈកម្មការស្ត្រីស្តីពីស្ថានភាពស្ត្រី លើកទី៦៣ ឆ្នាំ២០១៩** របស់អង្គការសហប្រជាជាតិស្តីពី ប្រព័ន្ធគាំពារសង្គមបានផ្តល់អនុសាសន៍សម្រាប់ការទទួលបានសេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចេរភាពដើម្បីសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្ត្រីដែលអនុសាសន៍នេះមានភាពប្រទាក់ក្រឡាគ្នាជាមួយនឹង **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤** ដែលផ្តោតទៅលើការបង្កើនល្បឿននៃកំណែទម្រង់អភិបាលកិច្ច ដែលចតុកោណទី១ បានកំណត់យកការអភិវឌ្ឍធនធានមនុស្សជាអាទិភាព និងបានចាត់ទុកការពង្រឹងសមភាពយេនឌ័រ និងកិច្ចគាំពារសង្គម ជាមាសភាពដ៏សំខាន់មួយ ។

ស្របជាមួយនឹងចក្ខុវិស័យទាំងឡាយខាងលើ រាជរដ្ឋាភិបាលបានដាក់ចេញនូវ **ក្របខ័ណ្ឌគោល-នយោបាយជាតិគាំពារសង្គម ២០១៦-២០២៥** ដែលបានផ្តល់នូវឧត្តមប្រយោជន៍ជាច្រើន ជាពិសេសដល់ស្ត្រីដែលមានផ្ទៃពោះ កុមារ ជនពិការ ជនចាស់ជរាគ្មានទីពឹងនិងផ្តល់ការគាំពារហានិភ័យលើផ្នែកសោធនថែទាំសុខភាព ហានិភ័យការងារ ពិការភាព និងដល់ប្រជាជនក្នុងវិស័យសេដ្ឋកិច្ចទាំងក្នុងនិងក្រៅប្រព័ន្ធ ព្រមទាំងផ្តល់ការគាំពារដល់ប្រជាជនដែលរស់នៅក្រោម និងក្បែរបន្ទាត់ភាពក្រីក្រ ដោយមិនទុកនរណាម្នាក់ឱ្យនៅឯកោរ។ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមនេះ មានលក្ខណៈទូលំទូលាយ និងផ្តោតលើសសរ ស្តម្ភពីរ គឺ ប្រព័ន្ធជំនួយសង្គម (Social Protection System) និងប្រព័ន្ធសន្តិសុខសង្គម (Social Security System)។ ការឆ្លើយតបទៅនឹងសមភាពយេនឌ័រ និងការគាំពារសង្គម គឺជាអភិក្រមគន្លឹះនៃការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ដើម្បីសម្រេចគោលដៅឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ តាមរយៈគោលនយោបាយជាតិនេះ កម្មករ កម្មការនីដែលធ្វើការនៅតាមរោងចក្រ សហគ្រាសបច្ចុប្បន្ននេះទទួលបានអត្ថប្រយោជន៍ធំៗពីរគឺការ គាំពារផ្នែកគ្រោះថ្នាក់ការងារនិងការគាំពារផ្នែកថែទាំសុខភាព។កម្មករ កម្មការនីរោងចក្រ ទទួលបានប្រាក់ខែគោលកើនឡើងដល់ ១៨២ដុល្លារ ក្នុងមួយខែ ចាប់ពីឆ្នាំ២០១៩ ហើយនឹងបន្តកើនឡើងនៅឆ្នាំបន្តបន្ទាប់ទៀត។ លើសពីនេះ ស្ត្រីដែលបំបៅដោះកូនត្រូវបានផ្តល់ពេល ១ម៉ោងក្នុងពេលម៉ោងធ្វើការរៀងរាល់ថ្ងៃ ដើម្បីបំបៅដោះកូន([1])។ នៅពេលសម្រាលកូន កម្មការនីរោងចក្រទទួលបានប្រាក់ឧបត្ថម្ភចំនួន ១០០ ដុល្លារទទួលបានការសម្រាកលំហែមាតុភាពមានរយៈពេលបីខែ ដោយទទួលបានប្រាក់ខែគោលពេញ ព្រមទាំងក្រោយសម្រាលទទួលបានប្រាក់ឧបត្ថម្ភ ១លានរៀលបន្ថែមទៀតពីរាជរដ្ឋាភិបាលកម្ពុជា។ រីឯមន្ត្រីរាជការ និងប្រជាពលរដ្ឋក្រីក្រដែលមានបណ្ណ ប.ស.ស និងបណ្ណសមធម៌ ក៏ទទួលបានការព្យាបាលដោយឥតបង់ប្រាក់ នៅតាមមន្ទីរពេទ្យរដ្ឋ និងមន្ទីពេទ្យដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស (NSSF)។ ប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាលចុះ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ បានបន្ថែមការយកចិត្តទុកដាក់ចំពោះស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំនៃគ្រួសារដែលមានប័ណ្ណសមធម៌ និងប័ណ្ណអាទិភាព ដោយផ្តល់នូវការឧបត្ថម្ភសាច់ប្រាក់ដែលចែកជា៣ដំណាក់កាល។ ដំណាក់កាលទី១៖ ផ្តល់ការឧបត្ថម្ភចំនួន ៤០ ០០០ រៀល ក្នុង១ដងសម្រាប់ការមកទទួលសេវាពិនិត្យផ្ទៃពោះ ដែលផ្តល់ជាអតិបរមាចំនួន៤ដង មុនពេលសម្រាល។ ដំណាក់កាលទី២៖ ផ្តល់ការ

---

[1]ច្បាប់ស្តីពីការងារ មាត្រា១៨៤

ឧបត្ថម្ភចំនួន ២០០ ០០០ រៀលតែ១ដងគត់នៅពេលសម្រាលកូននិងដំណាក់កាលទី៣៖ ផ្ដល់ការឧបត្ថម្ភចំនួន ៤០ ០០០ រៀលចំនួន១ដង ដែលផ្ដល់ជាអតិបរមាចំនួន១០ដង ក្នុងនោះ ៣ដង នៅពេលមកទទួលសេវាពិនិត្យសុខភាពក្រោយពេលសម្រាលកូនរួចនិង៧ដងនៅពេលយកកូនមកពិនិត្យថែទាំសុខភាពរហូតដល់អាយុ២ឆ្នាំ ក្នុងគោលបំណងលើកកម្ពស់ហេដ្ឋារចនាសម្ព័ន និងមូលដ្ឋានសុខាភិបាល ឱ្យឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ នៅឆ្នាំ២០១៨ ក្រសួងសុខាភិបាលក៏បានដាក់ចេញនូវសេចក្ដីណែនាំថ្នាក់ជាតិស្ដីពី ការសាងសង់មណ្ឌលសុខភាពត្រូវតែមានការរៀបចំឱ្យមាននូវបន្ទប់រង់ចាំសម្រាប់ស្ត្រីមានផ្ទៃពោះ សម្រាកបានមុនពេល និងក្រោយពេលសម្រាលកូន។

## ២.២-សមិទ្ធផលនៃការបញ្ជ្រាបយេនឌ័រតាមវិស័យនានា

ក្រសួងផែនការ ក្រសួងសុខាភិបាល និងក្រសួងកិច្ចការនារីសហការសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍន៍ បានធ្វើការសិក្សាស្រាវជ្រាវអំពើហិង្សាលើស្ត្រីពីដៃគូស្និតស្នាល ក្នុងឆ្នាំ ២០១៥ និងការអង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា ឆ្នាំ២០១៤ (CDHS 2014)ដែលជាលទ្ធផលបានបង្ហាញថា អំពើហិង្សាលើស្ត្រីពីដៃគូស្និតស្នាលមានការថយចុះ។វឌ្ឍនភាពនៃការកាត់បន្ថយគម្លាតយេនឌ័រនេះ ត្រូវបានស្ដែងឡើងថ្មីៗនេះ តាមរយៈការចំណាត់ថ្នាក់ប្រទេសកម្ពុជា ដោយវេទិកាសេដ្ឋកិច្ចពិភពលោក (World Economic Forum) ដែលបានបង្ហាញក្នុងឆ្នាំ២០១៨ កម្ពុជាមានចំណាត់ថ្នាក់ទី ៩៣ ដែលធៀបកាលពីឆ្នាំ ២០១៦ កម្ពុជាមានចំណាត់ថ្នាក់ទី ១១២គឺអាស្រ័យដោយភាពរីកចម្រើនយ៉ាងឆាប់រហ័សទាក់ទងនឹងកាលានុវត្តភាព និងការចូលរួមរបស់ស្ត្រីនិងក្មេងស្រី ។

**ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យសាធារណៈ និង នយោបាយ**មានការកើនឡើងគួរឱ្យកត់សម្គាល់។ ដើម្បីលើកកម្ពស់ស្ត្រីក្នុងវិស័យសាធារណៈនិងគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការជាក់លាក់ជាច្រើនក្នុងការបញ្ជ្រាបយេនឌ័រ និងបង្កើនតួនាទីស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចចិត្ត រួមទាំងការបញ្ចូលទៅក្នុងគោលនយោបាយជាតិ លិខិតបទដ្ឋានគតិយុត្តិនានានិងកម្មវិធីឬគម្រោងផ្សេងៗ។ តាមស្ថិតិបានបង្ហាញថា មានសមាមាត្រស្ត្រីនៅក្នុងរដ្ឋសភានៅឆ្នាំ២០០០ មាន ១២.៣% រីឯឆ្នាំ២០១៩ មានកំណើនរហូតដល់២០.៨% ។ ស្ត្រីជារដ្ឋមន្ត្រីនៅ ឆ្នាំ២០០០ មាន៧.៤% រីឯឆ្នាំ២០១៩ មាន១០.៣៤% ចំណែកឯស្ត្រីជារដ្ឋលេខាធិការនៅឆ្នាំ២០០០ មាន៦% រីឯឆ្នាំ២០១៩ មាន១៦.៣៦% និងស្ត្រីជាអនុរដ្ឋលេខាធិការ នៅឆ្នាំ២០០០ មាន ៤% រីឯឆ្នាំ ២០១៩ មាន១៦.៨៧%។ ចំណែកឯសមាមាត្រស្ត្រីក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់មាន ៩.៤% ឆ្នាំ២០០២ និងកើនឡើងដល់១៤% ឆ្នាំ២០១៩ (របាយការណ៍ក្រសួងកិច្ចការនារី ឆ្នាំ២០១៩)។ ស្ត្រីជាមន្ត្រីរាជការទូទាំងប្រទេសមាន ៤១% ក្នុងចំណោម មន្ត្រីរាជការសរុប (របាយការណ៍ក្រសួងមុខងារសាធារណៈឆ្នាំ២០១៩)។

ទោះបីជាមានកំណើនការចូលរួមរបស់ស្ត្រីយ៉ាងណាក្ដីក៏ការចូលរួមរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្ដីសម្រេចនៅតែពុំទាន់មានសមភាពនៅឡើយបើធៀបនឹងបុរស ដូចជាក្នុងចំណោមឧបនាយករដ្ឋមន្ត្រី ១០រូប មានស្ត្រីតែមួយរូបប៉ុណ្ណោះ ចំនួនស្ត្រីនៅក្នុងតួនាទីធ្វើសេចក្ដីសម្រេចចិត្តគឺមានតិចតួចបំផុត ក្នុងចំណោមរដ្ឋមន្ត្រីចំនួន ២៨រូប ក្នុងជួរ រដ្ឋាភិបាលមានតែ ៣រូបប៉ុណ្ណោះដែលជាស្ត្រី (ប្រភព៖ ព្រះរាជក្រមឆ្នាំ២០១៨)។

**ចាប់តាំងពីឆ្នាំ ២០១៤ វិស័យអប់រំ**នៅព្រះរាជាណាចក្រកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយចំនួនមនុស្សវ័យជំទង់ (អាយុចាប់ពី១៥ឆ្នាំ) ដែលចេះអាននិងសរសេរ មានការកើនឡើងរហូតដល់ ៨២.៥% ក្នុងនោះអត្រាបុរសដែលចេះអាន និងសរសេរមានរហូតដល់ ៨៧.៣% ខណៈដែលស្ត្រីមានត្រឹមតែ ៧៨.១%([2]) ។

**ការចូលរួមរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច**មានភាពសកម្ម និងកើនឡើងគួរឱ្យកត់សម្គាល់ ស្ត្រីកម្ពុជារួមទាំងជនទេសន្តរប្រវេសន៍បានក្លាយទៅជាកម្លាំងចលករ ដែលបានរួមចំណែកក្នុងការបង្កើនសេដ្ឋកិច្ចជាតិកន្លងមកហើយបច្ចុប្បន្នស្ត្រីមានកាលនុវត្តភាព ក្នុងការអភិវឌ្ឍចំណេះដឹង ជំនាញបច្ចេកទេស ដែលជាមូលដ្ឋានគ្រឹះក្នុងការចូលរួមប្រកួតប្រជែងប្រកបដោយ សក្តានុពលនៅក្នុងទីផ្សារសេដ្ឋកិច្ច ហើយជាអ្នកទទួលបានភាគផលពីកិច្ចអភិវឌ្ឍលើគ្រប់វិស័យដែលធ្វើឱ្យជីវភាពរស់នៅក្នុងក្រុមគ្រួសាររបស់គេមានភាពប្រសើរឡើង បានកាត់បន្ថយភាពងាយរងគ្រោះ និងរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ។ យោងតាមទិន្នន័យនៃអត្រាចូលរួមកម្លាំងពលកម្ម របស់ប្រជាជនអាយុពី ១៥ឆ្នាំ ទៅ ៦៤ឆ្នាំ របស់វិទ្យាស្ថានស្ថិតិនៃក្រសួងផែនការបានបង្ហាញឱ្យឃើញថា ស្ត្រីដែលមានអាយុចាប់ពី ២៥ឆ្នាំ ដល់ ៣៤ឆ្នាំ និងក្រុមអាយុពី ៣៥ឆ្នាំ ដល់ ៤៤ឆ្នាំ មានអត្រាខ្ពស់បំផុត គឺក្នុងចំណោម ១០នាក់ មានប្រហែល ៩នាក់បានចូលរួមក្នុងកម្លាំងពលកម្ម ហើយអត្រាសម្រាប់ក្រុមអាយុទាំងពីរនេះមានការកើនឡើងជាបន្តបន្ទាប់ ចាប់តាំងពីឆ្នាំ ២០០៩ រហូតដល់ឆ្នាំ២០១៧។ តួលេខនេះសបញ្ជាក់ឱ្យឃើញថា ស្ត្រីបានចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារនិងសង្គមជាតិ។ នៅអំឡុងឆ្នាំដដែលនេះយើងក៏សង្កេតឃើញថា ស្ថានភាពការងាររបស់ស្ត្រីដែលធ្វើការដើម្បី រួមចំណែកជួយដល់គ្រួសាររបស់ខ្លួនមានការប្រែប្រួលគួរឱ្យកត់សម្គាល់ដោយនៅក្នុងនោះ ភាគរយនៃនិយោជិតជាស្ត្រីទទួលប្រាក់បំណាច់បានកើនឡើងពី ២២,៨% ទៅ ៥៦,៦% នៅឆ្នាំ២០០៩ និងឆ្នាំ២០១៧ ស្របពេលដែលភាគរយស្ត្រីនៅក្នុងស្ថានភាពអ្នកធ្វើការងារឱ្យគ្រួសារមិនមានប្រាក់កម្រៃបានថយចុះខ្លាំងគឺ ពី ២៤,៥% ក្នុងឆ្នាំ២០០៩ ទៅ ៤% ក្នុងឆ្នាំ ២០១៧([3]) ។

ច្បាប់ និងគោលនយោបាយជាច្រើនត្រូវបានដាក់ចេញដើម្បីការពារសិទ្ធិរបស់ស្ត្រី ដែលក្នុងនោះមានរួមបញ្ចូលទាំងក្រមព្រហ្មទណ្ឌនិងក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ល។ ព្រមជាមួយគ្នានេះដែរ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣បានបញ្ចូលសូចនាករទាក់ទងនឹងសមភាពយេនឌ័រនិងជំរុញបន្ថែមទៀតដល់ក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការបញ្ជ្រាបយេនឌ័រនៅតាមវិស័យ។ យេនឌ័រត្រូវបានបញ្ជ្រាបក្នុងកម្មវិធីកំណែទម្រង់ជាតិសំខាន់ៗដូចជាកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងកម្មវិធីជាតិ១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការពង្រឹងយន្តការបញ្ជ្រាបយេនឌ័រ ដែលរួមបញ្ចូលទាំងក្រុមការងារបច្ចេកទេសយេនឌ័រជាផ្នែកមួយរបស់គណៈកម្មាធិការសម្របសម្រួលរវាង រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងដំណើរការរបស់ក្រុមការងារយេនឌ័រតាមក្រសួង

---

[2]CSES 2017

[3]អង្កេតសេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជា ឆ្នាំ២០១៧, វិទ្យាស្ថានស្ថិតិនៃក្រសួងផែនការ

ស្ថាប័នពាក់ព័ន្ធនានា។ ស្នើរគ្រប់ក្រសួង ស្ថាប័នបានរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យនៅថ្នាក់ក្រោមជាតិ។ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក)នៅថ្នាក់រាជធានី ក្រុង ស្រុក ខណ្ឌ បានបង្កើតឡើងដោយដើរតួនាទីក្នុងការផ្តល់យោបល់ និងលើកជាអនុសាសន៍ជូនដល់ក្រុមប្រឹក្សា គណៈអភិបាល អភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាលើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី និងកុមារនៅក្នុងរដ្ឋបាលរបស់ខ្លួន។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (គ.ក.ន.ក) ឃុំ-សង្កាត់ ក៏ត្រូវបានបង្កើតឡើងគ្រប់ឃុំ-សង្កាត់ទូទាំងប្រទេសផងដែរ។

## ៣. យេនឌ័រ និងសុខភាពនៅព្រះរាជាណាចក្រកម្ពុជា

ភាពខុសគ្នានៃភេទ ផ្នែកជីវសាស្ត្រប៉ះពាល់ដល់តម្រូវការផ្នែកសុខភាពរបស់បុរស និងស្ត្រី(ដូចជាមហារីកសុដន់ និងមហារីកប្រូស្តាត) ចំណែកឯភាពខុសគ្នាផ្នែកយេនឌ័រប៉ះពាល់ទៅលើរបៀបដែលស្ត្រី បុរស កុមារា និងកុមារីមកទទួលសេវាសុខភាព និងការការពារកត្តាប្រឈមនិងការលើកកម្ពស់សុខភាពរបស់ពួកគេ។ ខណៈដែលគោលការណ៍នៃសមភាពយេនឌ័រ និងដំណើរការនៃការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យសុខាភិបាល ត្រូវបានអនុម័តជាផ្លូវការដោយរាជរដ្ឋាភិបាលកម្ពុជា និងមានការសហការយ៉ាងជិតស្និតជាមួយដៃគូអភិវឌ្ឍន៍នានា និងអង្គការដៃគូក្នុងវិស័យសុខាភិបាល ក៏គម្លាតយេនឌ័រនៅតែកើតមាននៅឡើយទាំងស្ថានភាពនៃអ្នកផ្តល់សេវា និងអ្នកប្រើប្រាស់សេវាសុខាភិបាល។

### ៣.១-សមិទ្ធផលសម្រេចបាន

ព្រះរាជាណាចក្រកម្ពុជាបានលើកកម្ពស់របៀបវារៈសុខភាពរបស់ខ្លួន តាមរយៈហេដ្ឋារចនាសម្ព័ន្ធសុខភាពដែលកំពុងរីកចម្រើន កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ដែលនាំឱ្យស្ថានភាពរស់នៅមានភាពប្រសើរឡើង និងបង្កើនអាយុសង្ឃឹមរស់ពីកំណើត។ ក្នុងរយៈពេល១០ឆ្នាំ ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ ២០១៥ ប្រទេសកម្ពុជាមានការកើនឡើងអាយុសង្ឃឹមរស់ពីកំណើតសម្រាប់ស្ត្រីចាប់ពី ៦៨,៩៧ឆ្នាំ ដល់ ៧១,៥ឆ្នាំ([4])។ ការកែលម្អសេវាកម្មសម្រាប់ម្តាយ រួមទាំងការថែទាំមុនពេលសម្រាល និងក្រោយពេលសម្រាល ទំនងជាកត្តាជំរុញដ៏សំខាន់សម្រាប់ការសម្រេចបាននូវការកាត់បន្ថយអត្រាមរណភាពទារក និងកុមារអាយុក្រោម ៥ ឆ្នាំ។

ចំនួនមណ្ឌលសុខភាពបានកើនឡើងពី ១,១០៥ ក្នុងឆ្នាំ២០១៤ ដល់ ១,២០៥ និងមន្ទីរពេទ្យបង្អែកពី ៩៧ ដល់ ១២៣ក្នុងឆ្នាំ២០១៨។ ការផ្តល់ថ្នាំបង្ការដល់កុមារ និងចំនួនម្តាយដែលបំបៅកូនដោយទឹកដោះក៏បានកើនឡើងផងដែរ។

ចន្លោះពីឆ្នាំ២០១០ និងឆ្នាំ២០១៤ អត្រាមរណភាពមាតាបានធ្លាក់ចុះពី ២០៦ករណី មកត្រឹម ១៧០ករណីក្នុង ១០០.០០០ កំណើតរស់ ហើយអត្រាមរណភាពទារកបានថយចុះពី ៤៥ករណីមកត្រឹម២៨ករណីក្នុង ១,០០០ កំណើតរស់ យោងតាមទិន្នន័យ CDHS ២០១៤។ បច្ចុប្បន្ននេះ វត្តមាននៃបុគ្គលិកសុខាភិបាលមានជំនាញសម្រាប់ការសម្រាលកូនបានកើនឡើងដល់ ៨៥% និងសម្រាប់ការថែទាំក្រោយពេលសម្រាលបានកើនឡើងដល់៩០%។ ចំនួននៃការសម្រាលដោយការវះកាត់ក៏មានការកើនឡើងខ្ពស់ផងដែរ ចាប់តាំងពីការធ្វើឱ្យ

---

[4]ការត្រួតពិនិត្យដោយស្ម័គ្រចិត្ត២០១៩៖ ការអនុវត្តរបៀបវារៈឆ្នាំ២០៣០ នៃការអនុវត្តប្រកបដោយចេរភាព

ប្រសើរឡើងនៃវត្តមានរបស់បុគ្គលិកសុខាភិបាលដែលមានជំនាញ។ សម្រាប់ករណីសុខភាពបន្តពូជ នៅចន្លោះឆ្នាំ២០១០-២០១៤ (CDHS 2014) មានភាពវិជ្ជមាននៃការប្រើប្រាស់វិធីពន្យារកំណើត ខណៈការប្រើប្រាស់វិធីពន្យារកំណើតបានកើនឡើងពី ៥៤% ដល់ ៥៧% ។

អត្រាផ្តល់កំណើតសរុប (ចំនួនកូនកើតក្នុងស្ត្រីម្នាក់) បានធ្លាក់ចុះ0,៥នាក់ ក្នុងស្ត្រីម្នាក់នៅចន្លោះឆ្នាំ ២០០៥ និងឆ្នាំ២០១០ពី ៣,៤នាក់ដល់ ៣.0 នាក់ ក្នុងស្ត្រីម្នាក់ហើយថយចុះបន្តិចបន្តួចដល់ត្រឹម ២,៧ នាក់ក្នុងឆ្នាំ ២០១៤។

ការយល់ដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍ HIV/AIDS នៅព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈទូលំទូលាយ ស្ត្រីនិងបុរសដែលមានអាយុពី ១៥-១៩ ឆ្នាំ ស្ទើរតែទាំងអស់បានយល់ដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍ HIV/AIDS ខណៈដែលស្ត្រីមានការយល់ដឹងច្រើនជាងបុរស ដែលថា មេរោគអេដស៍HIV អាចចម្លងទៅកូនតាមរយៈការបំបៅដោះ ហើយការចម្លងនេះអាចកាត់បន្ថយបានដោយប្រើប្រាស់ថ្នាំពិសេស (៦០% ទល់នឹង ៥១%) CDHS ២០១៤។

ស្ថានភាពនៃជំងឺឆ្លងត្រូវបានគេដឹងថាមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងក្នុងចំណោមស្ត្រី និងបុរដោយសារតែភាពខុសគ្នានៃការប៉ះពាល់ និងការឆ្លើយតបផ្សារភ្ជាប់ទៅនឹងមុខងារ ទម្លាប់ បន្ទុកការងារ អាហារូបត្ថម្ភ ការបន្តពូជនិងការថែទាំកុមារ។ កត្តាជាច្រើនរួមចំណែកក្នុងការទទួលបានសេវាសុខភាពរបស់ស្ត្រីរួមមាន ផ្នត់គំនិតវប្បធម៌ ការធ្វើដំណើរ សន្តិសុខ បន្ទុកការងារ និងធនធាន...។ ជាធម្មតា ស្ត្រីដើរតួនាទីជាអ្នកផ្តល់ការថែទាំបឋម និងទទួលខុសត្រូវចំពោះការការពារ ការរកឃើញ និងការថែទាំជំងឺឆ្លងក្នុងចំណោមសមាជិកគ្រួសារ។ បុគ្គលិកនៅក្នុងវិស័យសុខាភិបាល ជាស្ត្រីមានចំនួន ៥២.៦% (ស្ថិតិបុគ្គលិកសុខាភិបាលឆ្នាំ២០១៩) ប៉ុន្តែមានចំនួនតិចនៅថ្នាក់គ្រប់គ្រង និងថ្នាក់ធ្វើការសម្រេចចិត្តហើយបុគ្គលិកស្ត្រីក៏ទទួលបានឱកាសបណ្តុះបណ្តាលតិចដែរ។ ទោះបីជាយ៉ាងណា គ្រប់ទិន្នន័យនៃប្រព័ន្ធតាមដាននិងឆ្លើយតបជំងឺឆ្លង មានការបែងចែកទៅតាមភេទ។

ការវិភាជថវិការដ្ឋ សម្រាប់សុខភាពបានកើនឡើងក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះដល់៤៨៧ លានដុល្លារ ក្នុងឆ្នាំ២០១៨។ សមធម៌ក្នុងការមកទទួលបានសេវាសុខភាព និងក្នុងហិរញ្ញប្បទានសុខាភិបាលត្រូវបានលើកស្ទួយជាបន្តបន្ទាប់ តាមរយៈការគ្របដណ្តប់នៃមូលនិធិសមធម៌នៅទូទាំងប្រទេសតាំងពីបំណាច់ឆ្នាំ ២០១៥ (២៣%) ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ រួមជាមួយគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកលែងការបង់ថ្លៃសេវាបានដករបាំងឧបសគ្គភូមិសាស្ត្រ និងរបាំងឧបសគ្គហិរញ្ញវត្ថុ ពោលគឺផ្តល់ការបង្ការហានិភ័យហិរញ្ញវត្ថុដល់គ្រួសារក្រីក្រឱ្យមកប្រើប្រាស់សេវាសុខភាពនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈដោយគ្មានបង់ថ្លៃ។ ប្រការនេះមិនត្រឹមតែជួយលើកកម្ពស់ស្ថានភាពសុខភាពប្រជាជនក្រីក្រឱ្យកាន់តែប្រសើរឡើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានការពារប្រជាពលរដ្ឋទាំងនោះកុំឱ្យធ្លាក់ខ្លួនទៅក្នុងភាពក្រីក្រដោយសារការចំណាយលើការថែទាំសុខភាពផងដែរ។ ទោះបីជាយ៉ាងណាក្តី គម្រោងមូលនិធិសមធម៌សុខភាព និងគម្រោងដទៃទៀតអាចកែលម្អស្ថានភាពបានដោយដោះស្រាយបញ្ហានៃការបាត់បង់ឱកាសយ៉ាងខ្ពស់សម្រាប់ស្ត្រី ដែលស្វែងរកការថែទាំសុខភាព (ដូចជា ការសម្រាលកូន ការធ្វើដំណើរពេលយប់ និងការថែទាំកូន)។

ការវិភាគយេនឌ័រនៃផ្នែកធនធានមនុស្សរបស់ក្រសួងសុខាភិបាលបានបង្ហាញថាបុគ្គលិកសុខាភិបាលជាស្ត្រីមានការកើនឡើងក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ពី ៨,០៧២នាក់(៤៤.៥៦%) ក្នុងឆ្នាំ២០១០ ដល់ ១៣,៧៨៦នាក់(៥២.៩៤%) នៅបំណាច់ឆ្នាំ២០១៩ តែភាគច្រើនស្ថិតនៅក្នុងប្រភេទមុខតំណែងជាឆ្មប មន្ត្រីធម្មតា និងជំនួយការប៉ុណ្ណោះ ជាមួយគ្នានេះដែរ ស្ត្រីកាន់មុខតំណែងមន្ត្រីសុខាភិបាលជាន់ខ្ពស់ក៏មានការកើនឡើង ពី ១៦៩នាក់ ក្នុងចំណោម ១,២០៩ (១៣.៩៨%) ក្នុងឆ្នាំ២០១៣ ដល់ ១៨៦នាក់ ក្នុងចំណោម ១,១៦០នាក់ (១៦.០៣%) ក្នុងឆ្នាំ២០១៩ ចាប់ពីថ្នាក់អគ្គនាយកដ្ឋានរហូតដល់អនុប្រធានការិយាល័យនៅថ្នាក់ជាតិ និងថ្នាក់ក្រោម ជាតិ។ វិសមភាពយេនឌ័រនៅក្នុងការអប់រំថ្នាក់មធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សាក៏រួមចំណែកដល់វិសមភាពនៅក្នុងតួនាទីរបស់សេវា សុខភាពផងដែរ។ ស្ត្រីមានប្រមាណ ២១.៦៧% (៥៩៣/២,៧៣៦) នៃវេជ្ជបណ្ឌិតផ្នែកជំងឺទូទៅ ១៥.៩១% (១០៩/៦៨៥) នៃវេជ្ជបណ្ឌិតឯកទេស ៣៣.០៥% (៩៣៦ /២,៨៣២) នៃ គិលានុបដ្ឋាកបឋម ៣៩.១៩% (៣០៨១ /៧,៨៦១) នៃគិលានុបដ្ឋាកមធ្យមនិង ១០០% (២,២៥១/២,២៥១) នៃឆ្មបបឋម (ស្ថិតិមន្ត្រីរាជការស៊ីវិលរបស់ក្រសួងសុខាភិបាល ឆ្នាំ២០១៩)។

ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ២០១៦-២០២០ គឺជាយុទ្ធសាស្ត្រផ្តល់មគ្គុទេសក៍ដល់ក្រសួងសុខាភិបាល និងអង្គភាពសុខាភិបាលទាំងអស់ ព្រមទាំងដៃគូពាក់ព័ន្ធ។ ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០ បញ្ជាក់ជាថ្មីពីចក្ខុវិស័យរយៈពេលវែងនៃការអភិវឌ្ឍវិស័យសុខាភិបាល និងដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ពង្រឹងប្រតិបត្តិការក្នុងវិស័យសុខាភិបាលទាំងមូល ទាំងផ្នែកសាធារណៈនិងឯកជន ដើម្បីដោះស្រាយបញ្ហាអាទិភាព និងធានាថាយុទ្ធសាស្ត្រវិស័យសុខាភិបាលត្រូវបានយកទៅអនុវត្តឱ្យមានសង្គតិភាពនៅក្នុងអន្តរាគមន៍នៃកម្មវិធីនានា។ ផែនការយុទ្ធសាស្ត្រក៏បានផ្តល់ក្របខ័ណ្ឌត្រួតពិនិត្យតាមដានវឌ្ឍនភាព និងវាយតម្លៃលទ្ធផលនៃការអនុវត្ត និងការធានាឱ្យមានសមភាពយេនឌ័រក្នុងវិស័យសុខាភិបាល។ ផែនការនឹងត្រូវបានប្រើប្រាស់ ដើម្បីកៀរគរធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ និងផ្តល់ព័ត៌មានដល់ការវិភាជន៍សារពើពន្ធព្រមទាំងតម្រង់ទិសជំនួយអភិវឌ្ឍក្នុងវិស័យសុខាភិបាល។

## ៣.២-បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផលសម្រេចបានជាច្រើន ក៏នៅមានបញ្ហាសេសសល់ មួយចំនួនដែលតម្រូវឱ្យក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលរួមគ្នាដោះស្រាយ ដូចជា៖

- ភាគរយស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅមានកម្រិតទាបនៅឡើយដែលទាមទារមានការយកចិត្តទុកដាក់ខ្ពស់លើការអនុវត្តគោលការណ៍បញ្ជ្រាបយេនឌ័រប្រកបដោយបរិយាបន្ន និងសមធម៌ ក្នុងការតែងតាំងមុខតំណែងគ្រប់គ្រងក្នុងវិស័យសុខាភិបាល។
- បុគ្គលិកនៅតាមមូលដ្ឋានព្យាបាលនិងថែទាំសុខភាពមួយចំនួនពុំទាន់គ្រប់តាមប្រភេទស្តង់ដារបុគ្គលិកដែលបានកំណត់ក្នុងសេចក្តីណែនាំស្តីពីសំណុំសកម្មភាពបង្គ្រប់(CPA) និងសេចក្តីណែនាំប្រតិបត្តិស្តីពីសំណុំសកម្មភាពអប្បបរមា(MPA)នៅឡើយ។

- គ្រប់ជនរងគ្រោះជាស្ត្រីនិងកុមារដែលមានបទពិសោធន៍ទទួលរងនូវអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទមិនទាន់បានស្វែងរកការអន្តរាគមន៍ពីសេវាសុខាភិបាលនៅឡើយ([5])។
- គម្លាតយេនឌ័រនៅតែកើតមាននៅស្ទើរតែគ្រប់កម្រិតនិងស្ថានភាព ជាពិសេសនៅតំបន់ជនបទដាច់ស្រយាល ដែលជាកត្តាប្រឈមដល់ស្ត្រី និងក្មេងស្រី ជនទេសន្តរប្រវេសន៍ ជនជាតិដើមភាគតិច ចាស់ជរា ជនស្រលាញ់ភេទដូចគ្នា។ល។ ក្នុងការទទួលបានសេវាសុខាភិបាលបានពេញលេញ និងឆ្លើយតបទៅតាមតម្រូវការជាក់ស្តែងរបស់ពួកគេ។
- សេចក្តីណែនាំ (Guideline) ស្តីពីការបញ្ជ្រាបយេនឌ័រមិនទាន់បានគ្របដណ្តប់គ្រប់ជ្រុងជ្រោយនៅក្នុងប្រព័ន្ធសុខាភិបាល។
- សមត្ថភាពរបស់មន្ត្រីពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអំពីការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យសុខាភិបាលនៅមានកម្រិត ដែលជាការចាំបាច់ត្រូវមានការពង្រឹងបន្ថែមជាបន្តបន្ទាប់។
- កិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធនៅគ្រប់កម្រិតក្នុងវិស័យសុខភាភិបាលនៅពុំទាន់បានពេញលេញដើម្បីជំរុញ ពង្រឹងការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យសុខភាភិបាលដោយផ្តោតលើអ្នកផ្តល់ និងអ្នកប្រើប្រាស់សេវាសុខាភិបាល។
- អត្រាមរណភាពមាតានៅតែមានកម្រិតខ្ពស់ បើធៀបនឹងស្តង់ដារអន្តរជាតិ។
- ចំណេះដឹងជាមូលដ្ឋានរបស់ប្រជាជនអំពីការថែទាំសុខភាពនៅមានកម្រិតដែលតម្រូវឱ្យក្រសួងសុខាភិបាល មូលដ្ឋានសុខាភិបាលគ្រប់កម្រិត និងដៃគូពាក់ព័ន្ធនានា បង្កើននិងពង្រឹងការផ្សព្វផ្សាយ និងផ្តល់ចំណេះដឹងបន្ថែមដល់ប្រជាជន ជាពិសេសនៅតំបន់ដាច់ស្រយាល ដើម្បីឱ្យមានកំណើនប្រើប្រាស់សេវាបន្ថែមទៀត។
- ក្នុងចំណោមប្រជាជនកម្ពុជាមានប្រជាជនវ័យក្មេងច្រើន ដែលពួកគេប្រឈមនឹងហានិភ័យនៃការឆ្លងមេរោគអេដស៍ ជំងឺកាមរោគ អំពើហិង្សា អំពើជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទជាដើម ហើយពួកគេជាក្រុមប្រជាជនដែលពិបាកក្នុងការកំណត់គោលដៅដើម្បីផ្តល់ចំណេះដឹងនិងចូលរួមក្នុងបណ្តាញដើម្បីទទួលបានសេវា([6])។

## ៤. គោលនយោបាយ

### ៤.១-ទស្សនៈវិស័យ

ប្រជាជនដែលត្រូវការសេវាសុខាភិបាល និងមន្ត្រីសុខាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជា ទទួលបានសមធម៌ដែលឆ្លើយតបផ្នែកយេនឌ័រល្អប្រសើរ។

### ៤.២-បេសកកម្ម

ផ្តល់នូវក្របខណ្ឌការងារយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងប្រព័ន្ធសុខាភិបាលដើម្បីសម្របសម្រួលការងារបញ្ជ្រាបយេនឌ័រក្នុងការធានានូវផលប្រយោជន៍ដល់មន្ត្រីសុខាភិបាល និងប្រជាជនដែលត្រូវការសេវាសុខាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសមធម៌ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍សុខភាព និងសុខុមាលភាពជាតិ។

---

[5]វិទ្យាស្ថានស្ថិតិ ឆ្នាំ២០១៥

[6]Unicef (2018), *Updated Situation Analysis of Children and Women in Cambodia,* Phnom Penh, Cambodia

## ៤.៣-គោលបំណង

បង្កើតបរិយាកាសដើម្បីសម្រេចឱ្យបានគុណភាពជីវិតកាន់តែប្រសើរ សម្រាប់មន្ត្រីសុខាភិបាល និងប្រជាជនកម្ពុជាគ្រប់រូបតាមរយៈការកាត់បន្ថយវិសមភាពយេនឌ័រនៅក្នុងវិស័យសុខាភិបាល

## ៤.៤-វិសាលភាព

គោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល សង្កត់ធ្ងន់លើមន្ត្រីសុខាភិបាល និងប្រជាជនដែលត្រូវការសេវាសុខាភិបាល ក្នុងព្រះរាជាណាចក្រកម្ពុជា ទាំងក្នុងផ្នែកសាធារណៈនិងឯកជន ។

## ៤.៥-គោលដៅនៃគោលនយោបាយ

បង្កើនលទ្ធភាពរបស់មន្ត្រីសុខាភិបាល និងប្រជាជនដែលត្រូវការសេវាសុខាភិបាល ឱ្យទទួលបានសមភាពយេនឌ័រក្នុងវិស័យសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

## ៤. ៦-យុទ្ធសាស្ត្ររបស់គោលនយោបាយ ( Guiding Principle )

- កែលម្អផែនការថវិការបស់ក្រសួងសុខាភិបាល ដើម្បីឆ្លើយតបទៅនឹងការងារយេនឌ័រ
- លើកកម្ពស់សមភាព នៃឱកាសនៅក្នុងការជ្រើសរើស ការបណ្តុះបណ្តាល ការកដំឡើងមុខតំណែង របស់មន្ត្រីរាជការនៃក្រសួងសុខាភិបាល
- បង្កើនការឆ្លើយតបរបស់កម្មវិធី និងការផ្តល់សេវាសុខាភិបាលឆ្លើយតបទៅនឹងការងារយេនឌ័រ
- បង្កើនការឆ្លើយតបជាប្រព័ន្ធលើករណីអំពើហិង្សាលើស្ត្រីសម្រាប់ប្រព័ន្ធសុខាភិបាល
- ពង្រឹងការទប់ស្កាត់ និងផលប៉ះពាល់លើផ្នែកចិត្តសង្គមនៃអំពើជួញដូរមនុស្សក្នុងវិស័យសុខាភិបាល
- ពង្រឹងសមត្ថភាពរបស់ GMAG ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីដោះស្រាយបញ្ហាឆ្លើយតបនឹង យេនឌ័រ ក្នុងក្រសួងសុខាភិបាល។

## ៤.៧-យុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបយេនឌ័រៈ

| ឋានានុក្រម នៃគោលបំណង | សូចនាករ | ទិន្នន័យដើមគ្រា | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|
| **គោលបំណង** បង្កើតបរិយាកាសដើម្បីសម្រេចឱ្យ បានគុណភាពជីវិតកាន់តែប្រសើរ សម្រាប់មន្ត្រីសុខាភិបាលនិងប្រជាជនកម្ពុជាគ្រប់រូបតាមរយៈកាត់បន្ថយវិសមភាពយេនឌ័រនៅក្នុងវិស័យសុខាភិបាល | អត្រាមរណភាពមាតាក្នុងចំណោម ១០០,០០០ កំណើតរស់ | ១៧០ | ១៣០ | | | | ១០០ | CDHS |
| | អត្រាផ្តល់កំណើតសរុប (ចំនួនកូនកើតក្នុងស្ត្រីម្នាក់) | ២,៧ | ២,១ | | | | | CDHS |
| | %មន្ត្រីរាជការសុខាភិបាលជាស្ត្រីក្នុងចំណោមមន្ត្រីរាជការសុខាភិបាលទាំងអស់ | ៥២,៦៥ | ៥២,៩៤ % | | | | | DP |
| **យុទ្ធសាស្ត្រទី១** កែលម្អផែនការថវិការបស់ក្រសួងសុខាភិ | %នៃប្រជាជនដែលគ្របដណ្តប់ដោយ ប្រព័ន្ធគាំពារសុខភាពសង្គម(មូលនិធិ | ២៣% | ៥០,០% | | | | | DPHI PCA |

| ឋានានុក្រម នៃគោលបំណង | សូចនាករ | ទិន្នន័យដើមគ្រា | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ឆ្លៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|
| បាល ដើម្បីឆ្លើយតបនឹងការងារយេនឌ័រ | សមធម៌ និងធានារ៉ាប់រងសុខភាព)-ចំនួនបុរស និងស្ត្រី | | | | | | | |
| **យុទ្ធសាស្ត្រទី២** ពង្រឹងសមភាពនៃឱកាសនៅក្នុងការជ្រើសរើស ការបណ្តុះបណ្តាល ការដំឡើងមុខតំណែងរបស់មន្ត្រីរាជការក្រសួងសុខាភិបាល | % នៃមណ្ឌលសុខភាពដែលមានឆ្មបយ៉ាងតិច ២នាក់ | ៩១% | ៩២% | ៩៣% | ៩៤% | ៩៥% | ៩៦% | DP |
| | យ៉ាងហោចណាស់មានបុគ្គលិកស្ត្រីម្នាក់នៅគ្រប់ក្រុមឆ្លើយតបបន្ទាន់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | ៦០% | > ៦០% | >៧០% | >៨០% | >៩០% | ១០០ % | CDCD |
| | %នៃការចូលរួមរបស់មន្ត្រីសុខាភិបាលជាស្ត្រីធៀបនឹងអ្នកបានចូលរួមសរុបនៅក្នុងសន្និសីទអន្តរជាតិ និងឱកាសបណ្តុះបណ្តាល | | ១៥% | ២០% | ២០% | ២០% | ២០% | HRD |
| | % នៃវេជ្ជបណ្ឌិតជាស្ត្រី ក្នុងចំណោមវេជ្ជបណ្ឌិតទាំងអស់ដែលប្រកបវិជ្ជាជីវៈនៅក្នុងក្របខណ្ឌក្រសួងសុខាភិបាល | ១៩,៣៤ | ១៩.៦ % | | | | ២០% | DP |
| | %ប្រធានមណ្ឌលសុខភាពជាស្ត្រី | ១៩.២% ២៣៤/ ១២២១ | ១៩.៤% | | | | ២០% | DP |
| | ចំនួនស្ត្រីដែលទទួលមុខតំណែងជាន់ខ្ពស់ក្នុងក្រសួង៖ *-អនុប្រធាននាយកដ្ឋានដល់អគ្គនាយក* | ៣៣ | ៣១ | | | | >៣១ | DP |
| | *-អនុប្រធានការិយាល័យស្រុកប្រតិបត្តិ និងថ្នាក់ប្រហាក់ប្រហែលឡើងទៅរហូតដល់អនុប្រធានមន្ទីរ* | ១៤៩ | ១៥៥ | | | | >១៥៥ | DP |
| | ចំនួនមន្ត្រីសុខាភិបាលទទួលបានការបណ្តុះបណ្តាលពីយេនឌ័រ និងសុខភាព | | ២០០ | ២០០ | ២០០ | ២០០ | ២០០ | CDC, GMAG |
| | ចំនួនមន្ត្រីសុខាភិបាលជាស្ត្រីដែលទទួលបាននូវការបណ្តុះបណ្តាល ពីការស្រាវ | ២៩ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | PMD |

| ឋានានុក្រម នៃគោលបំណង | សូចនាករ | ទិន្នន័យដើមគ្រា | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|
| | ជ្រាវរកជំងឺមហារីកមាត់ស្បូន | | | | | | | |
| | ចំនួនមន្ត្រីសុខាភិបាលជាស្ត្រីដែលទទួលបាននូវការបណ្តុះបណ្តាលពីការស្រាវជ្រាវរកជំងឺមហារីកសុដន់ | ២៩ | ៦០ | ៦០ | ៦០ | ៦០ | ៦០ | PMD |
| | %មន្ត្រីសុខាភិបាលជាស្ត្រីដែលទទួលបានការបណ្តុះបណ្តាល ផ្នែកសុខភាពផ្លូវចិត្ត និងភាពញៀនគ្រឿងញៀន(%នៃអ្នកដែលបានចូលរួមបណ្តុះបណ្តាលជាស្ត្រីធៀបនឹងសិក្ខាកាមចូលរួមសរុប) | ២០% | ២៣% | ២៦% | ២៩% | ៣១% | ៣៤% | DMHSA |
| | %មន្ត្រីសុខាភិបាលជាស្ត្រីទទួលបានការបណ្តុះបណ្តាលអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសម្រាប់សុខភាពសាធារណៈ(%នៃអ្នកដែលបានចូលរួមបណ្តុះបណ្តាលជាស្ត្រី) | ២០% | ២២% | ២៤% | ២៦% | ២៨% | ៣០% | PMD |
| **យុទ្ធសាស្ត្រទី៣** ការបង្កើនការឆ្លើយតបរបស់កម្មវិធី និងការផ្តល់សេវាសុខាភិបាលឆ្លើយតបទៅនឹងការងារយេនឌ័រ | %នៃស្ត្រីវ័យជំទង់អាយុ១៥-១៩ឆ្នាំដែលមានគភ៌ | ១២% | ៨,០% | | | | ៦,០% | MCH<br>CDHS<br>SDG |
| | %ស្ត្រីមានផ្ទៃពោះមកទទួលការពិនិត្យផ្ទៃពោះមុនសម្រាលយ៉ាងតិច ៤ដង | ៦៧% | ៨៨% | ៨៩% | ៩០% | ៩១% | ៩២% | MCH |
| | %នៃស្ត្រីសម្រាលទទួលការពិនិត្យថៃទាំក្រោយសម្រាលលើកទីមួយ (សប្តាហ៍ទី ១) | ៦៨,៤៦% | ៧០% | ៧០% | ៧០% | ៧១% | ៧២% | MCH |
| | %ស្ត្រីអាយុ ៣០-៤៩ឆ្នាំដែលបានទទួលការស្រាវជ្រាវរកជំងឺមហារីក មាត់ស្បូនយ៉ាងតិចមួយលើក | ០,៤% | ០,៦% | ០,៨% | ១% | ១,២% | ១,៤% | PMD |

| ឋានានុក្រម នៃគោលបំណង | សូចនាករ | ទិន្នន័យដើមគ្រា | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|
| | ចំនួនស្ត្រីអាយុ ៣០-៤៩ឆ្នាំ ដែលបានទទួលការស្រាវជ្រាវរកជំងឺមហារីក សុដន និងទទួលបានការបង្រៀនពីការស្ទាបរកដុំសាច់នៅលើសុដនរបស់ខ្លួន | ៤១៥,៤៦១ | ៤៦០,000 | ៥១0,000 | ៥៦0,000 | ៦១0,000 | | PMD |
| | ចំនួនប្រភេទសំភារៈអប់រំផ្សព្វផ្សាយនឹងត្រូវបានបង្កើតឡើងដោយផ្អែកលើការពិគ្រោះយោបល់លម្អិតជាមួយស្ត្រីនិងបុរសនៅក្នុងសហគមន៍ | | ៧ | ៨ | ៩ | ១០ | ១១ | របាយការណ៍កម្មវិធី NCHP |
| **យុទ្ធសាស្ត្រទី៤** បង្កើនការឆ្លើយតបជាប្រព័ន្ធលើករណីអំពើហិង្សាលើស្ត្រីនិងកុមារសម្រាប់ប្រព័ន្ធសុខាភិបាល | ចំនួនសកម្មភាពគន្លឹះឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹង យេនឌ័រត្រូវបានដាក់ចូលក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល | | | | | | | MCH |
| | ចំនួនបុគ្គលិកសុខាភិបាលដែលទទួលបានវគ្គបណ្តុះបណ្តាលអំពីការថែទាំ/ការឆ្លើយតបទៅនឹងស្ត្រីរងគ្រោះដោយអំពើហឹង្សា (ស្ត្រី) | ៥៨ | ៧០ | ១៤០ | ១៤០ | ១៤០ | ១៤០ (៦០% ជាស្ត្រី | MCH GMAG |
| | ចំនួនជនរងគ្រោះជាស្ត្រី និងកុមារដោយការរំលោភផ្លូវភេទមកទទួលសេវាកោសល្យវិច័យ (*) | ២៧៨ (២០១៨) | ២៥០ | ២៣០ | ២០០ | ១៧០ | ១៥០ | GMAG/ DHS/ MCH |
| | ចំនួនមូលដ្ឋានសុខាភិបាលដែលបាន បណ្តុះបណ្តាលអំពីការផ្តល់សេវាទាក់ទងនឹងអំពើហឹង្សាលើស្ត្រី | ១០១ | ១០១ | | | | | MCH |
| | ទិន្នន័យអំពីជនរងគ្រោះដោយអំពើហិង្សាបានបង្ហាញនៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល | | | | | | | MCH/ DPHI |
| | ចំនួនស្ត្រី និងកុមារី រងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ | ៥០ | ៥០ | | | | | MCH |

| ឋានានុក្រម នៃគោលបំណង | សូចនាករ | ទិន្នន័យដើមគ្រា | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|
| | ដែលទទួលបានសេវាសុខាភិបាល | | | | | | | |
| | ចំនួនមូលដ្ឋានសុខាភិបាលដែលមានកន្លែងផ្ដល់សេវាចម្រុះទាក់ទងនឹង GBV | 0 | ២ | | | | | GMAG |
| | ចំនួននិស្សិតបុរស និងនារីនៅក្នុងគ្រឹះស្ថានបណ្ដុះបណ្ដាលក្នុងវិស័យសុខាភិបាលទទួលបានការបណ្ដុះបណ្ដាលពីយេនឌ័រ ឬអំពើហិង្សាលើយេនឌ័រ | | | *ចាប់ផ្ដើមក្នុងឆ្នាំ ២០២១* | | | | HRD UHS GMAG |
| **យុទ្ធសាស្ត្រទី៥** ពង្រឹងការទប់ស្កាត់ និងផលប៉ះពាល់លើផ្នែកចិត្តសង្គមនៃអំពើជួញដូរមនុស្សក្នុងវិស័យសុខាភិបាល | ចំនួនមន្ត្រីសុខាភិបាលដែលបានបណ្ដុះបណ្ដាល និងទទួលបានចំណេះដឹងអំពីផលប៉ះពាល់លើផ្នែកចិត្តសង្គមបណ្ដាល មកពីការជួញដូរមនុស្ស | | | | | | | GMAG/ DMHSA/ IOM |
| | សៀវភៅគោលការណ៍ណែនាំស្ដីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សត្រូវបានបង្កើត | | | | | | ១ | GMAG/ DMHSA/ IOM |
| | ចំនួនមន្ត្រីសុខាភិបាលដែលបានបណ្ដុះបណ្ដាលអំពីគោលការណ៍ណែនាំស្ដីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស | | | | | | | GMAG/ DMHSA/ IOM |
| **យុទ្ធសាស្ត្រទី ៦** ពង្រឹងសមត្ថភាពរបស់ GMAG ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីដោះស្រាយបញ្ហានៃការឆ្លើយតបនឹងយេនឌ័រនៅក្នុងប្រព័ន្ធសុខាភិបាល | កម្មវិធីសិក្សាអំពីយេនឌ័រ និងសុខភាពបានធ្វើបច្ចុប្បន្នភាព | | ១ | | | | | GMAG |
| | ចំនួនគ្រូបង្គោលនៃក្រុមការងារបញ្ជ្រាបយេនឌ័រដែលបានបណ្ដុះបណ្ដាល | ៩ | ២០ | | | | | GMAG |
| | ចំនួនសិក្ខាសាលាប្រចាំឆ្នាំស្ដីពីវឌ្ឍនភាពនៃការអនុវត្តន៍គោលនយោបាយនិងផែនការយុទ្ធសាស្ត្រស្ដីពីការ | គ្មាន | ១ | ១ | ១ | ១ | ១ | GMAG |

| ឋានានុក្រម នៃគោលបំណង | សូចនាករ | ទិន្នន័យដើមគ្រា | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|
| | បញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល២០២០-២០២៤ | | | | | | | |
| | ចំនួនសិក្ខាសាលាពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងចុងបញ្ចប់នៃការអនុវត្តន៍គោលនយោបាយនិងផែនការយុទ្ធសាស្រ្តស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល ២០២០-២០២៤ ត្រូវបានរៀបចំ | គ្មាន | | | ១ | | ១ | GMAG |
| | ចំនួនអភិបាលពង្រឹងក្រុមការងារយេនឌ័រថ្នាក់រាជធានី-ខេត្ត | គ្មាន | ៥ | ១០ | ១២ | ១២ | ១២ | GMAG |
| | របាយការណ៍ប្រចាំឆមាសនិងឆ្នាំទាំងអស់រាយការណ៍បានគ្រប់ជ្រុងជ្រោយអំពីការអនុវត្តគោលនយោបាយនិងផែនការយុទ្ធសាស្រ្តស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល ២០២០-២០២៤ | | ២ | ២ | ២ | ២ | ២ | GMAG |
| | ចំនួនសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយនិងផែនការយុទ្ធសាស្រ្តស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិ បាល ២០២០-២០២៤ | | ១ | | | | | GMAG |
| | គោលនយោបាយនិងផែនការយុទ្ធសាស្រ្តស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល ២០២០-២០២៤ត្រូវបានបោះពុម្ពនិងចែកចាយដល់ GMAG និងដៃគូពាក់ព័ន្ធ | | ១០០០ | | | | | CDC |

| ឋានានុក្រម នៃគោលបំណង | សូចនាករ | ទិន្នន័យដើមគ្រា | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|
| | ប្រព័ន្ធប្រមូលទិន្នន័យតាមប្រព័ន្ធDigital បានបង្កើតនិងដំណើរការ | គ្មាន | | ១ | | | | GMAG |
| | សេចក្តីណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាលត្រូវបានបង្កើតនិងផ្សព្វផ្សាយដាក់ឱ្យអនុវត្តនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | | | | ១ | | | GMAG |

## ៥. ផែនការសកម្មភាព

| សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | អ្នកអនុវត្ត |
|---|---|---|---|---|---|---|
| **យុទ្ធសាស្ត្រទី១៖** កែលម្អផែនការថវិកា របស់ក្រសួងសុខាភិបាល ដើម្បីឆ្លើយតបនឹងការងារយេនឌ័រ | | | | | | |
| ១.១ រៀបចំធ្វើការវិភាគថវិកាយេនឌ័រទៅលើផែនការថវិកាជាតិ និងម្ចាស់ជំនួយគ្រប់កម្មវិធី របស់ក្រសួងសុខាភិបាលដើម្បីបង្កើតភ័ស្តុតាងសម្រាប់សមធម៌សុខភាពផ្នែកហិរញ្ញវត្ថុ | | | | | | GMAG |
| ១.២ រៀបចំការវិភាគយេនឌ័រនៃរបាំងផ្នែកទទួលសេវា ចំពោះការទទួលបានមូលនិធិសមធម៌សុខភាពនៅតំបន់ជនបទ | | | | | | DPHI/ GMAG |
| ១.៣ រៀបចំផែនការសកម្មភាព នៅក្នុងសមាសភាគទី3នៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុ ដើម្បីបង្កើនការឆ្លើយតបនឹងយេនឌ័ររបស់គម្រោងមូលនិធិសមធម៌សុខភាព/ឧបត្ថម្ភធន (ដូចជា ដោះស្រាយបញ្ហាបាត់បង់ឱកាសពាក់ព័ន្ធនឹងយេនឌ័រ) | | | | | | DPHI |
| ១.៤ តស៊ូមតិស្នើសុំការដាក់បញ្ចូលការកែសម្រួលដែលឆ្លើយតបនឹងយេនឌ័រ ទៅក្នុងការគ្របដណ្តប់មូលនិធិសមធម៌សុខភាពដែលពង្រីកថ្មី | | | | | | GMAG, MOWA |
| **យុទ្ធសាស្ត្រទី២៖ ពង្រឹងសមភាពនៃឱកាសនៅក្នុងការជ្រើសរើស ការបណ្តុះបណ្តាល ការដំឡើងមុខតំណែងរបស់មន្ត្រីក្រសួងសុខាភិបាល** | | | | | | |
| ២.១ ជ្រើសរើសឆ្មបយ៉ាងតិច 2 នាក់ក្នុងមួយមណ្ឌលសុខភាព | | | | | | DP |
| ២.២ ជ្រើសរើសឆ្មបមធ្យមឱ្យបានយ៉ាងតិចចំនួន ១០០ នាក់បន្ថែមទៀតក្នុង១ឆ្នាំ ដែលត្រៀមធ្វើការរយៈពេលយ៉ាងតិចពីរឆ្នាំនៅក្នុងតំបន់ជនបទនិងដាច់ស្រយាល | | | | | | DP |
| ២.៣ ស្រាវជ្រាវប្រតិបត្តិស្តីពីការអនុវត្តកញ្ចប់លើកទឹកចិត្តសម្រាប់ឆ្មបដែលធ្វើការនៅតំបន់ដាច់ស្រយាល (ដូចជា ដោះស្រាយការចំណាយលើការផ្លាស់ប្តូរទីលំនៅ សន្តិសុខ ការថែទាំកូន) | | | | | | GMAG |

| សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | អ្នកអនុវត្ត |
|---|---|---|---|---|---|---|
| ២.៤ គស៊ូមតិស្នើសុំបង្កើតគម្រោង "លើកទឹកចិត្តសម្រាប់ឆ្មបដែលធ្វើការនៅតំបន់ដាច់ស្រយាល" នៅក្នុងបរិបទនៃការពិភាក្សាទូលំទូលាយអំពីកញ្ចប់លើកទឹកចិត្តសម្រាប់បុគ្គលិកសុខាភិបាលដែលធ្វើការនៅតំបន់ | | | | | | GMAG, NRHP |
| ២.៥ សិក្សាស្ថិតិមន្ត្រីផ្នែកឆ្លើយតបបន្ទាន់ដោយមានបែងចែកតាមភេទ ដើម្បីធានាឱ្យមានយ៉ាងហោចស្ត្រីម្នាក់នៅក្នុងក្រុមឆ្លើយតបបន្ទាន់នីមួយៗ | | | | | | CDCD |
| ២.៦ រៀបចំការវិភាគលើវិធីនានាដែលទិដ្ឋភាពយេនឌ័រ (ដូចជាឱកាសអប់រំ) អាចត្រូវបានដោះស្រាយដើម្បីកាត់បន្ថយគម្លាតរវាងការចូលរៀនរបស់ស្ត្រីនិងបុរសក្នុងការបណ្តុះបណ្តាលមូលដ្ឋាន និងបណ្តុះបណ្តាលបន្ត និងផ្សព្វផ្សាយលទ្ធផល | | | | | | GMAG, MOWA |
| ២.៧ ផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុសម្រាប់ការចូលរួមរបស់ស្ត្រីម្នាក់សម្រាប់រាល់បុរសម្នាក់ដែលបានចាត់តាំងឱ្យចូលរួមក្នុងសន្និសីទអន្តរជាតិ ឬឱកាសបណ្តុះបណ្តាល (ប្រមាណ ប្រាំមួយនាក់ប្រចាំឆ្នាំ) | | | | | | GMAG, HRD/DIC |
| ២.៧ រៀបចំការបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងដែលឆ្លើយតបនឹងយេនឌ័រសម្រាប់សមាជិក សមាជិកា GMAG | | | | | | GMAG, DP/HRD |
| ២.៨ រៀបចំរបាយការណ៍បែងចែកតាមភេទ ស្តីពីប្រភេទនិងចំនួនបុគ្គលិកក្នុងក្រសួងសុខាភិបាល | | | | | | DP |
| ២.៩ រៀបចំចំណុចដៅសម្រាប់ប្រភេទក្របខ័ណ្ឌការងារនិងល្បាយជំនាញនៃសមាសភាពកម្លាំងការងាររបស់ក្រសួងសុខាភិបាលពេលអនាគត | | | | | | DP |
| ២.១០ រៀបចំយន្តការត្រួតពិនិត្យតាមដាននិងផ្សព្វផ្សាយសម្រាប់វឌ្ឍនភាពនៅក្នុងការកាត់បន្ថយគម្លាតយេនឌ័រនៅក្នុងការដំឡើងឋានៈតាមតំបន់ ក្របខ័ណ្ឌការងារ និងមុខតំណែង | | | | | | GMAG |
| ២.១១ កំណត់រក និងផ្តល់អនុសាសន៍ដល់បេក្ខនារីដែលមានសមត្ថភាពសម្រាប់រាល់ឱកាសដំឡើងមុខតំណែងនីមួយៗ | | | | | | GMAG |
| ២.១២ ជំរុញ និងលើកទឹកឱ្យសិក្ខាកាមជាស្ត្រីចូលរួមក្នុងវគ្គបណ្តុះបណ្តាលអំពីជំងឺមហារីកមាត់ស្បូន ជំងឺមហារីកសុដន់ ផ្នែកសុខភាពផ្លូវចិត្ត និងភាពញៀនគ្រឿងញៀន | | | | | | PMD DMHSA |
| **យុទ្ធសាស្ត្រទី៣៖ ការបង្កើនការឆ្លើយតបរបស់កម្មវិធី និងការផ្តល់សេវាសុខាភិបាលឆ្លើយតបទៅនឹងការងារយេនឌ័រ** | | | | | | |
| ៣.១ បង្កើនការគ្របដណ្តប់ និងលទ្ធភាពទទួលបានសេវាសុខភាពបន្តពូជមានគុណភាព ជាពិសេសសម្រាប់ ស្ត្រីបុរសវ័យជំទង់ | | | | | | MCH |
| ៣.២ បង្កើនការគ្របដណ្តប់ និងលទ្ធភាពទទួលបានសេវាថែទាំគត៌មុនសម្រាល សម្រាលមានសុវត្ថិភាព ថែទាំក្រោយសម្រាល | | | | | | MCH |

| សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | អ្នកអនុវត្ត |
|---|---|---|---|---|---|---|
| សេវាសម្ភពសង្គ្រោះបន្ទាន់ និងថែទាំទារកមានគុណភាព ព្រមទាំងសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន | | | | | | |
| ៣.៣ ផ្សព្វផ្សាយ ផ្តល់ប្រឹក្សា អប់រំ យុទ្ធនាការ ផលិត IEC, SBC, និងពង្រីកការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គម | | | | | | MCH |
| ៣.៤ ពង្រីកការចុះអប់រំផ្សព្វផ្សាយតាម សហគមន៍ | | | | | | PMD |
| ៣.៥ អប់រំផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ និងបណ្តាញសង្គម | | | | | | PMD |
| ៣.៦ រៀបចំយុទ្ធនាការផ្សព្វផ្សាយ និងទិវាប្រយុទ្ធនឹងមហារីក | | | | | | PMD |
| ៣.៧ រៀបចំគម្រោងផែនការថវិកានិងកាលវិភាគនៃការផលិតសំភារៈ ចែកចាយនិងផ្សព្វផ្សាយពាក់ព័ន្ធនឹងជំងឺឆ្លង | | | | | | CDC<br>NCHADS<br>CNM<br>CENAT<br>NCHP |
| **យុទ្ធសាស្ត្រទី៤៖ បង្កើនការឆ្លើយតបជាប្រព័ន្ធលើករណីអំពើហិង្សាលើស្ត្រីនិងកុមារសម្រាប់ប្រព័ន្ធសុខាភិបាល** | | | | | | |
| ៤.១ ដាក់បញ្ចូលសកម្មភាពឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល | | | | | | GMAG<br>MCH |
| ៤.២ ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាលស្តីពីការថែទាំ/ឆ្លើយតបទៅនឹងស្ត្រីរងគ្រោះដោយអំពើហិង្សា | | | | | | GMAG<br>MCH |
| ៤.៣ ពិនិត្យតាមដានពីរដងក្នុងមួយឆ្នាំ | | | | | | MCH |
| ៤.៤ បណ្តុះបណ្តាលអ្នកផ្តល់សេវា | | | | | | MCH |
| ៤.៥ ចុះផ្សព្វផ្សាយដល់សហគមន៍ | | | | | | MCH |
| ៤.៦ កែសម្រួលសមាសភាពគណៈកម្មការកោសល្យវិច័យថ្នាក់ជាតិ-ក្រោមជាតិ | | | | | | DHS |
| ៤.៧ បង្កើនឧបករណ៍បច្ចេកទេសធ្វើកោសល្យវិច័យ | | | | | | DHS/MCH |
| ៤.៨ ផ្តល់ការបណ្តុះបណ្តាលឯកទេសដល់មូលដ្ឋានសុខាភិបាលដែលទទួលខុសត្រូវព្យាបាលជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទ រួមទាំងជំនាញសំភាសន៍សមស្រប ការពិនិត្យ ការព្យាបាល (ដូចជា ការបង្ការក្រោយពេលប៉ះពាល់) ការរាយការណ៍ និងការបញ្ជូន | | | | | | GMAG/<br>MCH/ |
| ៤.៨ កែលម្អការប្រមូល និងការបញ្ចូលទិន្នន័យអំពីជនរងគ្រោះដោយអំពើហិង្សានៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល | | | | | | MCH/<br>DPHI |
| ៤.៩ ពង្រឹង ការប្រឹក្សាសម្រាប់អ្នកជំងឺដែលមកពិនិត្យនិងព្យាបាល បញ្ហាសុខភាពដោយសារតែអំពើហិង្សាផ្លូវភេទ | | | | | | GMAG/<br>MCH/ |
| ៤.១០ បង្កើតប្រព័ន្ធរបាយការណ៍ដោយប្រើ App | | | | | | GMAG/<br>MCH |
| ៤.១១ បង្រៀនពីរបៀបកត់ត្រា និងរាយការណ៍ | | | | | | GMAG/<br>MCH |
| ៤.១២ បង្កើតកន្លែងផ្តល់សេវាចម្រុះសម្រាប់ជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅក្នុងមន្ទីរពេទ្យ | | | | | | GMAG/<br>MCH |
| **យុទ្ធសាស្ត្រទី៥៖ ពង្រឹងការទប់ស្កាត់ និងផលប៉ះពាល់លើផ្នែកចិត្តសង្គមនៃអំពើជួញដូរមនុស្សក្នុងវិស័យសុខាភិបាល** | | | | | | |

| សកម្មភាព | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ | អ្នកអនុវត្ត |
| --- | --- | --- | --- | --- | --- | --- |
| ៥.១ ផ្តល់ការបណ្តុះបណ្តាលមន្ត្រីសុខាភិបាលអំពីផលប៉ះពាល់លើផ្នែកចិត្ត-សង្គម បណ្តាលពីអំពើជួញដូរមនុស្ស | | | | | | GMAG/ DMHSA/ IOM |
| ៥.២ រៀបចំគោលការណ៍ ណែនាំស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរ មនុស្សក្នុងវិស័យសុខាភិបាល | | | | | | GMAG/ DMHSA/ IOM |
| ៥.៣ ផ្តល់ការបណ្តុះបណ្តាលមន្ត្រីសុខាភិបាលអំពីគោលការណ៍ណែនាំស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស | | | | | | GMAG DMHSA/ IOM |
| **យុទ្ធសាស្រ្តទី៦៖ ពង្រឹងសមត្ថភាពរបស់ GMAG ដើម្បីដោះស្រាយបញ្ហានៃការឆ្លើយតបនឹងយេនឌ័រនៅក្នុងក្រសួងសុខាភិបាល** | | | | | | |
| ៦.១ សហការជាមួយ FHI360 រៀបចំធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាអំពីយេនឌ័រ និងសុខភាព | | | | | | GMAG FHI360 |
| ៦.២ ផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្គោលដល់សមាជិក GMAG | | | | | | GMAG |
| ៦.៣ រៀបចំសិក្ខាសាលាប្រចាំឆ្នាំដើម្បីត្រួតពិនិត្យការអនុវត្តន៍គោលណយោបាយផែនការយុទ្ធសាស្រ្តស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល | | | | | | GMAG CDC ADB-GMS And others |
| ៦.៤ រៀបចំសិក្ខាសាលាពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិការអនុវត្តន៍ គោលណយោបាយផែនការយុទ្ធសាស្រ្តស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល២០២០-២០២៤ | | | | | | GMAG CDC ADB-GMS And others |
| ៦.៥ ចុះអភិបាលពង្រឹងក្រុមការងារយេនឌ័រថ្នាក់រាជធានីខេត្ត | | | | | | GMAG |
| ៦.៦ បង្កើតប្រព័ន្ធប្រមូលទិន្នន័យតាមប្រព័ន្ធ Digital និងដាក់ឱ្យដំណើរការ | | | | | | GMAG |
| ៦.៧ ស្វែងរកធនធាននិងទីប្រឹក្សាបច្ចេកទេសដើម្បីរៀបចំសេចក្តីណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល និងផ្សព្វផ្សាយដាក់ឱ្យអនុវត្តនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | | | | | | GMAG |
| ៦.៨ ធ្វើរបាយការណ៍រៀងរាល់ឆមាស | | | | | | GMAG |

## ៦. ការលើកកម្ពស់អភិបាលកិច្ចនៅទូទាំងប្រព័ន្ធសុខាភិបាលស្តីពីការធានាបញ្ជ្រាបយេនឌ័រ

- អភិបាលកិច្ចប្រព័ន្ធសុខាភិបាលមានបំណង ជំរុញឱ្យមានការធ្វើសកម្មភាពរួមគ្នា ទាំងនៅក្នុង និងក្រៅវិស័យសុខាភិបាលរវាងសុខាភិបាលសាធារណៈ និងឯកជន និងសហគមន៍ដើម្បីលើកកម្ពស់លទ្ធផលការបញ្ជ្រាបយេនឌ័រ អនុលោមតាមកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ លេខាធិការដ្ឋានក្រុមការងារបញ្ជ្រាបយេនឌ័រស្ថិតនៅក្រោមនាយកដ្ឋានរដ្ឋបាល នៃក្រសួងសុខាភិបាលបំពេញតួនាទីជានាយកដ្ឋានបង្គោលនៅថ្នាក់ជាតិក្នុងការសម្របសម្រួលការងារបញ្ជ្រាបយេនឌ័រ ក្នុងប្រព័ន្ធសុខាភិបាលថ្នាក់ជាតិថ្នាក់ក្រោមជាតិ ក្រសួងពាក់ព័ន្ធនិងអន្តរជាតិ។នាយកដ្ឋានរដ្ឋបាលដឹកនាំការអនុវត្ត ការធ្វើបច្ចុប្បន្នភាព១) គោលនយោបាយ និងផែនការយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល ២) ដាក់បញ្ចូលផែនការយេនឌ័រទៅក្នុងផែនការប្រចាំឆ្នាំរបស់ក្រសួងសុខាភិបាល ៣). ធ្វើការផ្សព្វផ្សាយការអនុវត្តផែនការប្រចាំឆ្នាំនេះដល់មន្ត្រីសុខាភិបាលដែលពាក់ព័ន្ធ ៤). អភិវឌ្ឍសេចក្តីណែនាំ ឧបករណ៍វាយតម្លៃនិងបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងការងារយេនឌ័រ សម្រាប់ដាក់ឱ្យអនុវត្តក្នុងប្រព័ន្ធសុខាភិបាល។

- បង្កើតក្រុមការងារបច្ចេកទេសថ្នាក់ក្រោមជាតិក្នុងមន្ទីរសុខាភិបាលរាជធានីខេត្ត ក្រោមការសម្របសម្រួលរបស់ថ្នាក់ជាតិ ដើម្បីបំពេញមុខងារ និងភារកិច្ចទាក់ទងនឹងការងារបញ្ច្រាបយេនឌ័រ របស់មន្ទីរសុខាភិបាលរាជធានីខេត្ត។ សមាជិកភាព និងការទទួលខុសត្រូវរបស់ក្រុមការងារនេះ ត្រូវសម្រេច ដោយរដ្ឋបាលរាជធានីខេត្ត។
- ចាត់តាំងមន្ត្រីជំនាញពាក់ព័ន្ធជាមន្ត្រីបង្គោលដើម្បីបំពេញតួនាទីក្នុងការដាក់បញ្ចូលផែនការសកម្មភាព និងថវិកាការងារបញ្ជ្រាបយេនឌ័រក្នុងនាយកដ្ឋាន មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរសុខាភិបាល រាជធានី ខេត្ត។ ក្រុមការងារបច្ចេកទេសនិងមន្ត្រីបង្គោលត្រូវទទួលបានការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកយេនឌ័រ និងទទួលបានអត្ថប្រយោជន៍ សមស្របផ្សេងទៀតដើម្បីបំពេញការងារបញ្ជ្រាបយេនឌ័រ។
- ស្វែងរកការគាំទ្រពីរដ្ឋបាលថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ/អន្តរជាតិ និងដៃគូដើម្បីធានានិរន្តភាពនូវការអនុវត្តគោលនយោបាយនិងផែនការយុទ្ធសាស្ត្រស្តីពីការងារបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល។
- ពិនិត្យគោលនយោបាយដែលមានស្រាប់ និងគោលនយោបាយថ្មីៗ ព្រមទាំងស្នើផ្តល់យោបល់បច្ចេកទេសសម្រាប់គោលនយោបាយសុខភាព រួមទាំងការងារបញ្ជ្រាបយេនឌ័រ ក្នុងនាយកដ្ឋាន ស្ថាប័នក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ពង្រឹងកិច្ចសហការជាមួយអង្គភាពវិជ្ជាជីវៈនានាដើម្បីសម្រេចបានការផ្តល់សេវាសុខភាពផ្តោតលើការបញ្ជ្រាបយេនឌ័រ ប្រកបដោយគុណភាពខ្ពស់។

## ៧. កញ្ចប់ថវិកាសម្រាប់ការងារបញ្ជ្រាបយេនឌ័រ

គោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល២០១៩-២០២៣ ត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីកៀងគរធនធានថវិកាជាតិ ថវិកាដៃគូអភិវឌ្ឍនិងប្រភពថវិកាស្របច្បាប់ផ្សេងទៀតឱ្យបានគ្រប់គ្រាន់ ដើម្បីជួយដល់ក្រុមការងារបញ្ជ្រាបយេនឌ័រធ្វើការទៅលើការបញ្ជ្រាបយេនឌ័រនៅក្នុងប្រព័ន្ធសុខាភិបាលក្រសួងសុខាភិបាលទទួលបានជោគជ័យគ្រប់ជ្រុងជ្រោយ។

## ៨. ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ

ក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួងសុខាភិបាលនឹងរៀបចំសិក្ខាសាលាឬកិច្ចប្រជុំដើម្បីពិនិត្យឡើងវិញលើលទ្ធផលប្រចាំឆ្នាំមួយ និងរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំលម្អិតរៀងរាល់ឆ្នាំ ដោយផ្អែកលើការណែនាំទូទៅដែលមានកំណត់នៅក្នុងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល២០១៩-២០២៣។

ការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាលស្ថិតនៅក្នុងកម្រិតខ្ពស់ក្នុងក្របខ័ណ្ឌក្រសួងសុខាភិបាល ហើយក្រុមការងារយេនឌ័រនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការនេះ។លេខាធិការដ្ឋានក្រុមការងារបញ្ជ្រាបយេនឌ័រនឹងទទួលខុសត្រូវចំពោះការរៀបចំផែនការចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃនូវការអនុវត្តការងារទៀងទាត់និងធ្វើរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំអំពីសមិទ្ធផលដែលសម្រេចបាន។

ការត្រួតពិនិត្យតាមដានជាប្រចាំនៃផែនការសកម្មភាព និងការចំណាយ នឹងត្រូវដាក់បញ្ចូលគ្នារាល់ឆមាសពីរបាយការណ៍របស់នាយកដ្ឋានរដ្ឋបាលនៃក្រសួងសុខាភិបាលដោយក្រុមការងារយេនឌ័រ ដោយប្រើទម្រង់របាយការណ៍លទ្ធផលសាមញ្ញមួយ ដែលអាចបំពេញតាមប្រព័ន្ធ Digital និងពិភាក្សាគ្នាក្នុងកិច្ចប្រជុំពិនិត្យឡើងវិញប្រចាំឆ្នាំ។ ការចុះអភិបាលពង្រឹងក្រុមការងារយេនឌ័រថ្នាក់រាជធានី-ខេត្តនឹងត្រូវធ្វើឡើងយ៉ាងទៀងទាត់ព្រមទាំងមានការវាយតម្លៃខាងក្រៅពាក់កណ្តាលអាណត្តិនិងចុងបញ្ចប់នឹងត្រូវធ្វើឡើងនៅពេលមានជំនួយផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសពីដៃគូអភិវឌ្ឍនានារបស់ក្រសួងសុខាភិបាល។គោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល២០១៩-២០២៣នឹងត្រូវធ្វើបច្ចុប្បន្នភាពតាមការចាំបាច់តាមការរីកចម្រើននៃការងារយេនឌ័រក្នុងវិស័យសុខាភិបាល។

## ៩. សេចក្តីសន្និដ្ឋាន

ការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាលគឺជាជំហានដ៏សំខាន់មួយក្នុងការលើកកម្ពស់ការយកចិត្តទុកដាក់ចំពោះសុខភាពប្រជាជន។ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល២០១៩-២០២៣នេះ គឺជាភស្តុតាងនៃការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំក្នុងការផ្តួចផ្តើមគំនិត ដើម្បីឱ្យមន្ត្រីសុខាភិបាលគ្រប់កម្រិត និងអ្នកពាក់ព័ន្ធអនុវត្តការងាររបស់ខ្លួនក្នុងក្របខណ្ឌជាក់លាក់។

គោលនយោបាយ និងផែនការយុទ្ធសាស្ត្រព្រមទាំងផែនការសកម្មភាពជាក់លាក់ស្តីពីការបញ្ជ្រាបយេនឌ័រនឹងត្រូវធ្វើការផ្សព្វផ្សាយ និងពង្រីកការអនុវត្តន៍ដល់មន្ត្រីសុខាភិបាលសាធារណៈ និងឯកជនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជា។

ការចូលរួមការបង្កើនការយល់ដឹង ការបណ្តុះបណ្តាលមន្ត្រីសុខាភិបាល និងការគាំទ្រពីដៃគូអភិវឌ្ឍគឺមានសារៈសំខាន់ណាស់ ក្នុងការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខាភិបាល ២០១៩-២០២៣ ប្រកបដោយភាពជោគជ័យ។

## ១០. ឯកសារយោង


1. គោលដៅអភិវឌ្ឍដោយចេរភាព (SDG)
2. រាជរដ្ឋាភិបាលកម្ពុជា, យុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៤
3. ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦-២០២៥)
4. ក្រសួងសុខាភិបាល, ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០
5. ក្រសួងសុខាភិបាល, ផែនការយុទ្ធសាស្ត្របញ្ញាបយេនឌ័រ ឆ្នាំ ២០១៤-២០១៨
6. ព្រះរាជាណាចក្រកម្ពុជា, ច្បាប់ស្តីពីការងារ មាត្រា១៨៤
7. ក្រសួងផែនការ, CDHS 2014
8. ព្រះរាជក្រម្យ ឆ្នាំ២០១៨ ស្តីពីការតែងតាំងរដ្ឋមន្ត្រីអាណត្តិទី៥
9. ក្រសួងសុខាភិបាល, ស្ថិតិបុគ្គលិកសុខាភិបាល ឆ្នាំ២០១៩
10. ក្រសួងកិច្ចការនារី, របាយការណ៍ ឆ្នាំ ២០១៩
11. ក្រសួងមុខងារសាធារណៈ , របាយការណ៍មន្ត្រីរាជការស៊ីវិល ឆ្នាំ ២០១៩
12. ក្រសួងសុខាភិបាល អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាលនាយកដ្ឋានមន្ទីរពេទ្យ។ សេចក្តីណែនាំប្រតិបត្តិស្តីពីសំណុំសកម្មភាពអប្បបរមា ។ខែឧសភាឆ្នាំ២០១៨។
13. ក្រសួងផែនការ, វិទ្យាស្ថានជាតិស្ថិតិ, ការអង្កេតសេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជា ឆ្នាំ២០១៧
14. ការត្រួតពិនិត្យដោយស្ម័គ្រចិត្ត២០១៩៖ ការអនុវត្តរបៀបវារៈឆ្នាំ២០៣០ នៃការអនុវត្តប្រកបដោយចេរភាព
15. វិទ្យាស្ថានស្ថិតិ ឆ្នាំ២០១៥
16. ក្រសួងសុខាភិបាល សេចក្តីព្រាងគោលនយោបាយសុខភាពទេសន្តរប្រវេសន៍២០២០
17. Unicef (2018), *Updated Situation Analysis of Children and Women in Cambodia,* Phnom Penh, Cambodia


---

*(*): សូចនាករណ៍សមិទ្ធផលសេវាកោសល្យវិច័យត្រូវបានកំណត់តិចជាងក្នុងឆ្នាំបន្តបន្ទាប់មានគោលបំណងដើម្បីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធសហគម និងពលរដ្ឋគ្រប់រូបត្រូវរួមគ្នាទប់ស្កាត់ការរំលោភផ្លូវភេទលើស្ត្រីនិងកុមារព្រមទាំងអំពើហឹង្សាដទៃទៀតតាមភារកិច្ចរៀងៗខ្លួន។ករណីមានចំនួនលើសពីការកំណត់នេះជនរងគ្រោះដោយការរំលោភផ្លូវភេទនៅតែទទួលបានសេវាកោសល្យវិច័យតាមតម្រូវការ។*

# ១១. ឧបសម្ព័ន្ធ

## ១១.១-បញ្ជីវាក្យស័ព្ទបច្ចេកទេសយេនឌ័រ

**យេនឌ័រ៖** គឺសំដៅយកតួនាទី ឥរិយាបថ និងតម្លៃទាំងឡាយដែលវប្បធម៌នានា និងសង្គមដាក់កំណត់ ឱ្យបុរស និងស្ត្រីអនុវត្តដោយឡែកពីគ្នាពីតួនាទី ឥរិយាបថ ហើយគុណតម្លៃទាំងនេះកំណត់នូវអាកប្បកិរិយា និងទំនាក់ទំនងរវាងបុរស និងស្ត្រី។ តួនាទី ឥរិយាបថ និងគុណតម្លៃទាំងនេះ ត្រូវបានបង្កើតឡើង និងថែរក្សាដោយស្ថាប័នសង្គមនានា ដូចជា គ្រួសារ រដ្ឋាភិបាល សហគមន៍ សាលារៀន វត្តអារាម និងសារព័ត៌មាន។

**ភេទ៖** សំដៅភាពខុសគ្នាតាមធម្មជាតិ និងលក្ខណៈជីវសាស្ត្រ ដែលកំណត់មនុស្សណាមួយថាជាបុរស ឬស្ត្រី។ ភេទសំដៅយកលក្ខណៈរូបរាងកាយ និងសរីរាង្គរបស់មនុស្សម្នាក់ៗ។

**ការយល់ដឹងពីយេនឌ័រ៖** ការយល់ដឹងអំពីភាពខុសគ្នារវាងបុរស និងស្ត្រីដែលសង្គមបានកំណត់ឡើងដោយឈរលើចំណេះដឹងស្តីពីអាកប្បកិរិយានានា ដែលជះឥទ្ធិពលទៅលើសមត្ថភាពនៃការទទួលបាន និង ការគ្រប់គ្រងធនធានឱកាស និងផលប្រយោជន៍។

**គម្លាតយេនឌ័រ៖** ជាគម្លាតរវាងបុរស និងស្ត្រីនៅក្នុងការចូលរួម ការទទួលបានសិទ្ធិ ឱកាស និងការគ្រប់គ្រងលើធនធាន និងផលប្រយោជន៍នៅក្នុងវិស័យណាមួយ។

**សមភាពយេនឌ័រ៖** ជាដំណើរការនៃការប្រព្រឹត្តដោយយុត្តិធម៌ទៅលើស្ត្រី និងបុរស ដើម្បីបន្ថយគម្លាតយេនឌ័រ និងឱ្យមានសមភាពយេនឌ័រ។

**ការវិភាគយេនឌ័រ៖** សំដៅលើដំណើរការវិភាគ និងពិនិត្យហ្មត់ចត់លើតួនាទីរបស់បុរស និងស្ត្រី ដោយរួមបញ្ចូលបញ្ហាគន្លឹះនានា ដូចជា ការបែងចែកកម្លាំងពលកម្ម សកម្មភាព ផលិតកម្ម និងការបន្តពូជ ការទទួលបាន និងការគ្រប់គ្រងធនធាន តម្រូវការ និងផលប្រយោជន៍ កត្តាសង្គម និង សេដ្ឋកិច្ចនានា ដែលមានឥទ្ធិពលលើបុរស និងស្ត្រី។ ការវិភាគយេនឌ័រត្រូវធ្វើឡើងនៅគ្រប់ជំហាននៃការរៀបចំផែនការកម្មវិធី គម្រោង ដោយចាប់ផ្តើមពីការកំណត់អាទិភាព ការប្រមូលទិន្នន័យ ការរៀបចំ ការអនុវត្តន៍ ការតាមដាន និងវាយតម្លៃកម្មវិធី និងគម្រោង។

**ការបញ្ជ្រាបយេនឌ័រ៖** ជាការដាក់បញ្ចូលបញ្ហា និងតម្រូវការរបស់បុរស និងស្ត្រីទៅក្នុងការវិភាគ ការប៉ាន់ប្រមាណ និងការតាមដានត្រួតពិនិត្យការរៀបចំ និងអនុវត្តកម្មវិធី គម្រោង គោលនយោបាយ និងច្បាប់នានា ដើម្បីធានាថាបុរស និងស្ត្រីបានចូលរួមក្នុងការអនុវត្តធ្វើសេចក្តីសម្រេច និងទទួលផលប្រយោជន៍ស្មើគ្នា។

**ការឆ្លើយតបយេនឌ័រ៖** ជាការដោះស្រាយតម្រូវការ បញ្ហា និងផលប្រយោជន៍ខុសគ្នារវាងបុរសស្ត្រី កុមារា កុមារី ដើម្បីជៀសវាងការសន្មតថា បុរស ស្ត្រី និងកុមារា កុមារី ស្ថិតក្នុងស្ថានភាពដូចគ្នា។

**ថវិកាឆ្លើយតបនឹងយេនឌ័រ៖** ជាការធានាថា បញ្ហា តម្រូវការ ផលប្រយោជន៍ និងការចូលរួមរបស់បុរសស្ត្រី និងកុមារា កុមារីត្រូវបានដោះស្រាយ និងដាក់បញ្ចូលនៅពេលរៀបចំ និងវិភាគថវិកាសម្រាប់ការអនុវត្តកម្មវិធី គម្រោង ឬសកម្មភាពផ្សេងៗ។ ថវិកាយេនឌ័រ ដែលមានប្រសិទ្ធភាពត្រូវ ធានាថា បញ្ហាយេនឌ័រត្រូវបានវិភាគ និងដោះស្រាយចាប់តាំងពីការរៀបចំអនុវត្ត តាមដាន និងវាយតម្លៃគម្រោង និងកម្មវិធី។

**ទិន្នន័យបែងចែកតាមភេទ៖** ជាស្ថិតិដែលពិពណ៌នាពីស្ថានភាពខុសគ្នារវាងបុរសស្ត្រី និងកុមារ កុមារី ជាឧទាហរណ៍ចំនួនមន្ត្រីរាជការជាបុរស និងស្ត្រី ឬចំនួនកុមារា កុមារីកំពុងរៀននៅកម្រិតបឋមសិក្សា។

**យេនឌ័រ និងការអភិវឌ្ឍ៖** យុទ្ធវិធីម្យ៉ាង ដែលយកចិត្តទុកដាក់ខ្លាំងទៅលើវិសមភាព នៃទំនាក់ទំនងរវាងបុរស និងស្ត្រី ដែលបណ្តាលមកពី ភាពលម្អៀងក្នុងការបំពេញមុខងារនៅក្នុងសង្គម។

**ភាពមិនមានទស្សនៈយេនឌ័រ៖** ជាការមិនទទួលស្គាល់ និងមិនយកចិត្តទុកដាក់លើបញ្ហា តម្រូវការ និងការទទួល ផលប្រយោជន៍ខុសគ្នារវាងបុរស និងស្ត្រីក្នុងការទទួលបានធនធាន ការធ្វើការសម្រេចចិត្ត និងតួនាទីខុសគ្នារវាងបុរស និងស្ត្រី។ គោលនយោបាយមិនមានទស្សនៈយេនឌ័រសន្មត់ថាពុំមានភាពខុសគ្នារវាងបុរស និងស្ត្រីទេ។

**ការវិភាគផលប៉ះពាល់លើយេនឌ័រ៖** ការវិភាគពីការជះឥទ្ធិពលនៃគោលនយោបាយ ឬកម្មវិធីមួយទៅលើបុរស និងស្ត្រីរូបភាពផ្សេងៗគ្នា។

**តួនាទីយេនឌ័រ ទំនាក់ទំនងសង្គមនៃយេនឌ័រ៖** គឺជាតួនាទីរបស់បុរស និងស្ត្រីដែលកំណត់ដោយសង្គម។ ទំនាក់ទំនងសង្គមនៃយេនឌ័រពន្យល់ឱ្យឃើញច្បាស់អំពីភាពមិនឆ្លុះ (ស៊ីមេទ្រីគ្នា) ដែលកើតឡើងជាទូទៅក្នុងទំនាក់ទំនងរវាងបុរស និងស្ត្រី ដោយផ្អែកលើតួនាទីភេទ និងការបែងចែកអំណាច ក្នុងការសម្រេចចិត្ត ការបែងចែកពលកម្មទាំងនៅក្នុងផ្ទះ និងទាំងនៅក្នុងសង្គមទាំងមូល។ ទំនាក់ទំនងសង្គមនិងយេនឌ័រនេះ ធ្វើឱ្យយើងចាប់អារម្មណ៍ដោយចំពោះទៅលើលក្ខណៈសម្បត្តិទាំងឡាយដែលទទួលបាន តាមរយៈសង្គមរូបនីយកម្មការឲ្យ និយមន័យអំពីក្រុម និងអំពីខ្លួនយើង ការដឹងពីតួនាទី គុណតម្លៃ និងអាកប្បកិរិយាសមស្របរបស់យើង។ ហើយលើសពីនេះទៀត គឺដឹងពីអន្តរសកម្មភាពដែលរំពឹងទុក និងអាចទទួលយកបានក្នុងទំនាក់ទំនងរវាងបុរស និងស្ត្រីផងដែរ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ ៧១០ សនប

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពក្រុមការងារយេនឌ័រក្រសួងសុខាភិបាល

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- បានឃើញសេចក្តីសម្រេចលេខ ៦២៣ ស.នប ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការបង្កើតក្រុមការងារយេនឌ័រក្រសួងសុខាភិបាល

## សម្រេច

**ប្រការ១.** ត្រូវបានកែសម្រួលសមាសភាពក្រុមការងារយេនឌ័ររបស់ក្រសួងសុខាភិបាល ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១.លោកជំទាវ | **តាន់ ឡូចឆេង** | រដ្ឋលេខាធិការ | ប្រធាន |
| ២.លោកជំទាវ | **ឱ វណ្ណឌីន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣.លោកជំទាវ | **ប៉ែន រិតស៊ី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤.លោកជំទាវ | **ប្រាក់ សោភ័ណនារី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៥.លោកស្រីសាស្ត្រាចារ្យ | **ទុខ រដ្ឋាវី** | ប្រធានមជ្ឈ.គាំពារមាតា និងទារក | អនុប្រធាន |
| ៦.លោក | **ហុក ខៀវ** | ប្រធាននាយកដ្ឋាននីតិកម្ម | អនុ.អចិន្ត្រៃយ៍ |
| ៧.លោកស្រីវេជ្ជ. | **ម៉ែន នារីសុជាតិ** | នាយករងមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ | អនុប្រធាន |
| ៨.លោកវេជ្ជ. | **អ៊ីវ សុបុណ្ណា** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ៩.លោកស្រី | **ម៉ម សុថាវី** | អនុប្រធាននាយកដ្ឋានថវិកានិងហិរញ្ញវត្ថុ | សមាជិក |
| ១០.លោកស្រីឱសថ. | **ឈឹម ម៉ាលី** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក | សមាជិក |
| ១១.លោកវេជ្ជ. | **ចេង មុនី** | អនុ.នា.ផែនការ និងព័ត៌មានសុខាភិបាល | សមាជិក |
| ១២.លោកស្រីវេជ្ជ. | **ខន ស៊ីនួន** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ | សមាជិក |

| | | | |
|---|---|---|---|
| ១៣.លោកវេជ្ជ. | **ង៉ែត សុវណ្ណា** | អនុប្រធាននាយកដ្ឋានការពារសុខភាព | សមាជិក |
| ១៤.លោកវេជ្ជ. | **ភីម សាឱ្ចន** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ | សមាជិក |
| ១៥.លោកស្រីវេជ្ជ. | **គេង ស្រី** | អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | សមាជិក |
| ១៦.លោក | **នុន សុវឌ្ឍនា** | អនុប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ១៧.លោកទន្ត. | **តាំ ស៊ីឡុន** | អនុប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ១៨.លោកស្រីវេជ្ជ. | **ឡាក់ មួយស៊ាង** | អនុប្រធាននាយកដ្ឋានការពារសុខភាព | សមាជិក |
| ១៩.លោកស្រីវេជ្ជ. | **ហួត ចាន់ធានី** | នាយករងមន្ទីរពេទ្យកុមារជាតិ | សមាជិក |
| ២០.លោកស្រីវេជ្ជ. | **ចក ធីតា** | នាយករងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | សមាជិក |
| ២១.លោកវេជ្ជ. | **ឡាន វណ្ណាសេង** | អនុ.មជ្ឈ.ប្រយុទ្ធនឹងជំងឺអេដស៍សើស្បែកនិងកាមរោគ | សមាជិក |
| ២២.លោកស្រីវេជ្ជ. | **សុខ សូរតេនា** | អនុប្រ. មជ្ឈ.ស្រាវជ្រាវវេជ្ជសាស្ត្របុរាណ | សមាជិក |
| ២៣.លោកស្រីវេជ្ជ. | **ហាវ រ័ត្ននារី** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវេជ្ជសាស្ត្រ | សមាជិក |
| ២៤.លោកស្រីវេជ្ជបណ្ឌិត | **ភីម រតនា** | អនុប្រធានមជ្ឈ.គាំពារមាតា និងទារក | សមាជិក |
| ២៥.លោកស្រីវេជ្ជ. | **ម៉ូខេង ថាវរីន** | អនុប្រធានមជ្ឈ.ប្រយុទ្ធនឹងជំងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ | សមាជិក |
| ២៦.លោក | **គង់ ស្រួន** | ប្រធានការិ.ត្រួតពិនិត្យ នៃអគ្គាធិការដ្ឋាន | សមាជិក |
| ២៧.លោក | **អៀន សុខគី** | ប្រធានការិ.នាយកដ្ឋានការពារសុខភាព | សមាជិក |
| ២៨.លោកស្រី | **សាត ពិសី** | ប្រធានការិ.រដ្ឋបាល នៃនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ២៩.លោកវេជ្ជ. | **សោម សីហារ័ត្ន** | អនុការិ.និយ័តកម្ម និងក្រមសីលធម៌នៃនាយកដ្ឋានមន្ទីរពេទ្យ | សមាជិក |
| ៣០.លោកស្រីឱសថការី | **ឆាយ រដ្ឋធានី** | អនុ.ការិ.នាយកដ្ឋានឱសថចំណីអាហារ បរិក្ខាពេទ្យ និងគ្រឿងសំអាង | សមាជិក |
| ៣១.លោកស្រីវេជ្ជ. | **ណុប សុធារតនៈ** | មជ្ឈ.កំចាត់រោគរបេង និងហង់សិន | សមាជិក |
| ៣២.លោកវេជ្ជ. | **ហេង ម៉ុណ្ណា** | មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព | សមាជិក |
| ៣៣.លោកស្រីសាស្ត្រាចារ្យ | **អ៊ឹម សិទ្ធិភារុ** | មន្ទីរពេទ្យកាល់ម៉ែត | សមាជិក |
| ៣៤.លោកស្រី | **ចិន សុខា** | មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | សមាជិក |
| ៣៥.លោកស្រី | **ជាម ស៊ីនិត** | មជ្ឈមណ្ឌលជាតិផ្តល់ឈាម | សមាជិក |
| ៣៦.លោកស្រីឱសថ. | **យស់ សុល្លតា** | មន្ទីរពេទ្យព្រះអង្គឌួង | សមាជិក |
| ៣៧.លោកស្រីវេជ្ជបណ្ឌិត | **ឡាំ គីរុណា** | មជ្ឈ.គាំពារមាតា និងទារក | សមាជិក |
| ៣៨.លោកស្រី | **ហួត មាលតី** | នា.សុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន | សមាជិក។ |

**ប្រការ២**. ក្រុមការងារយេនឌ័រមានភារកិច្ចដូចខាងក្រោម៖

-សម្របសម្រួល សហការនិងស្វែងរកការគាំទ្រថវិកា និងបច្ចេកទេសពីបណ្តាស្ថាប័ននិងដៃគូអភិវឌ្ឍន៍ដើម្បីលើកកម្ពស់ការងារយេនឌ័រ

-ផ្សព្វផ្សាយ និងបណ្តុះបណ្តាលចំណេះដឹងផ្នែកយេនឌ័ររបស់ក្រសួងសុខាភិបាល ដល់មន្ត្រីសុខាភិបាលនៅថ្នាក់កណ្តាល រាជធានី ខេត្ត និងមូលដ្ឋានសុខាភិបាល

-ចូលរួមផ្តល់យោបល់ និងជម្រុញមន្ត្រីសុខាភិបាលជាស្ត្រីឲ្យទទួលបានការបណ្តុះបណ្តាល និងមុខតំណែងតាម

សមត្ថភាព

-ចូលរួមរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ដើម្បីធានាថា ផែនការនេះឆ្លើយតបនឹងយេនឌ័រ

-ទំនាក់ទំនង និងសហការជាមួយក្រុមការងារយេនឌ័រនៃក្រសួងកិច្ចការនារី ដើម្បីរៀបចំនិងអនុវត្តការងារផ្សេងៗ ដែលទាក់ទងនឹងការងារយេនឌ័រ

-ធ្វើផែនការសកម្មភាពការងារយេនឌ័រប្រចាំឆ្នាំ

-បញ្ជ្រាបទស្សនៈយេនឌ័រទៅគ្រប់កម្មវិធីរបស់ក្រសួងសុខាភិបាល

-ត្រួតពិនិត្យ និងវាយតម្លៃរាល់សកម្មភាពដែលបានអនុវត្តពាក់ព័ន្ធនឹងការងារយេនឌ័រ។

**ប្រការ៣.** ត្រូវបានបង្កើតលេខាធិការដ្ឋានស្ថិតនៅនាយកដ្ឋានរដ្ឋបាល ដើម្បីជួយដល់ក្រុមការងារយេនឌ័ររបស់ក្រសួងសុខាភិបាល ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១.លោកសាស្ត្រាចារ្យ | **អ៊ឹម សាខួន** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ | ប្រធាន |
| ២.លោកស្រីវេជ្ជ. | **ថែម ទិរាវណ្ណា** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣.លោក | **នុន សុវឌ្ឍនា** | អនុប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៤.លោកស្រីឱសថ. | **ឈឹម ម៉ាលី** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក | សមាជិក |
| ៥.លោកស្រីវេជ្ជ. | **ឡាក់ មួយស៊ាង** | អនុប្រធាននាយកដ្ឋានការពារសុខភាព | សមាជិក |
| ៦.លោកស្រី | **ហែម ណាវី** | ប្រធានការិយាល័យថែទាំគិលានុបដ្ឋាកនិងឆ្មប | សមាជិក |
| ៧.លោកស្រី | **អៀ ដារ៉ាវី** | មន្ត្រីនាយកដ្ឋានមន្ទីរពេទ្យ | សមាជិក |
| ៨.កញ្ញា | **ឆាយ ភារម្យ** | មន្ត្រីនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៩.លោក | **អ៊ុច រតនា** | មន្ត្រីនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | សមាជិក។ |

**ប្រការ៤.** លេខាធិការដ្ឋានក្រុមការងារយេនឌ័រមានភារកិច្ចដូចខាងក្រោម ៖

-ជួយសម្របសម្រួលការងាររដ្ឋបាលទូទៅ ឲ្យក្រុមការងារយេនឌ័ររបស់ក្រសួងសុខាភិបាល

-ប្រមូល និងបូកសរុបរបាយការណ៍អំពីស្ថានភាពយេនឌ័រ និងសកម្មភាពដែលក្រុមការងារយេនឌ័រ អនុវត្តទាំងក្នុង និងក្រៅក្រសួងសុខាភិបាល ជូនដល់ថ្នាក់ដឹកនាំក្រសួងសុខាភិបាលនិងក្រសួងកិច្ចការនារី

-រក្សាទុករាល់ឯកសារពាក់ព័ន្ធនឹងការងារយេនឌ័រ ។

**ប្រការ៥.** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦.** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានរាយនាមក្នុងប្រការ១ និងប្រការ៣ ត្រូវទទួលភារៈអនុវត្ត តាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១១ ៣ ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៩

**កន្លែងទទួល**

-ក្រសួងកិច្ចការនារី

-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

-ខុទ្ទកាល័យក្រសួងសុខាភិបាល

-ដូចប្រការ៦

-ឯកសារ -កាលប្បវត្តិ

ក្រសួងសុខាភិបាល

**ម៉ម ប៊ុនហេង**